ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ១៥ ត្រីមាសទី០១ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦២ ស្ដីពី ការផ្ដល់គោរមងារ អស់លោក ៣រូប ជាឧកញ៉ា ១៧៦៣

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងទេសចរណ៍ ១៥រូប ១៧៦៤

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ លោកស្រី **ចំរើន មុនិតា** ១៧៦៥

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៥ ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោកស្រី **ឃួន នីតា** នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការស្នើសុំរបស់សាមីខ្លួន ១៧៦៦

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៦ ស្ដីពី ការតែងតាំងមុខតំណែង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៅក្រសួងព័ត៌មាន ដល់មន្ត្រីរាជការ ៥រូប ១៧៦៨

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៧ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈដល់ឯកឧត្ដម **ស គន្ធា** ជាទីប្រឹក្សាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានឋានៈ ស្មើអគ្គនាយក ១៧៧០

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៦៨ ស្ដីពី ការតែងតាំងលោកជំទាវ **គឹម ណេខ** ជាទីប្រឹក្សាក្រសួងបរិស្ថាន ដោយពុំទទួលប្រាក់បំណាច់មុខងារ ១៧៧១

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៧៦ ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈដល់លោក **ធន់ ផុន** នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមការស្នើសុំរបស់សាមីខ្លួន ១៧៧២

២៧-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៧៧ ស្ដីពី ការដំឡើងនិងតែងតាំង ឯកឧត្ដម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ពីសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មកជា អនុប្រធានទី៣ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១៧៧៤

២៨-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៧៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្ដម **ស្តេហ្វាន់ ម៉េស៊ើរ៉េរ** (Stefan MESSERER) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ១៧៧៥

២៨-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៧៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក **កុយ សាវរិទ្ធ** ១៧៧៦

២៨-១-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០១២៦/១៨០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ៨រូប ១៧៧៧


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៩-១-២០២៦ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៧៧៨

| | | |
|---|---|---|
| ១៩-១-២០២៦ | -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ១៨១៣ |
| ២០-១-២០២៦ | -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៧ | ១៨១៧ |
| ២០-១-២០២៦ | -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្ដីពី ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីនគរបាលជាតិ | ១៨១៩ |
| ២០-១-២០២៦ | -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ក្រសួងមហាផ្ទៃ | ១៨២១ |
| ២០-១-២០២៦ | -អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ១៨២៣ |
| ២១-១-២០២៦ | -អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ១៨២៥ |
| ២១-១-២០២៦ | -អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ១៨២៦ |
| ២១-១-២០២៦ | -អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ១៨២៧ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៨៦ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ១៨៣៣ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ១៨៣៥ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ១៨៣៧ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ១៨៣៩ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា | ១៨៤១ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ១៨៤៣ |
| ២២-១-២០២៦ | -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ១៨៤៥ |


## ២~សេចក្ដីសម្រេច


| | | |
|---|---|---|
| ១៩-១-២០២៦ | -សេចក្ដីសម្រេចលេខ ១០ សសរ ស្ដីពី ការចាត់តាំងរដ្ឋលេខាធិការប្រចាំការ | ១៨៥០ |


## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២-១២-២០២៥ | -ប្រកាសលេខ ៩៨១ សហវ.ប្រក.អលសា ស្ដីពី ការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម | ១៨៥២ |


### ២~ធនាគារជាតិ នៃ កម្ពុជា


| | | |
|---|---|---|
| ១៩-២-២០២៦ | -ប្រកាសលេខ ធ៣៧.០២៦.១១៣.ប្រក ស្ដីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម | ១៨៦១ |


### ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងការពារជាតិ


| | | |
|---|---|---|
| ៨-១-២០២៦ | -ប្រកាសលេខ ០០៩ ប្រក.កពជ ស្ដីពី ការបង្កើតស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាល ទាំង ៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ | ១៨៧៣ |

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

**ផ្តល់គោរមងារ៖**

១- លោក **ឡេង ប៉ី**

២- លោក **ឈិន ខុស៊ីយ៉ុង**

៣- លោក **ឈី ជែម**

ជា

**ឧកញ៉ា**

ពរល.២៦០១.១៦៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងទេសចរណ៍ ១៥រូប៖

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោក គង់ វិបុល

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោក គង់ សុភារក្ស

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោក សយ ស៊ីណុល

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១- លោក សំ វុទ្ធា ២- លោក សុខ វណ្ណា

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១- ឯកឧត្តម ឆាយ យុនឡុង ២- លោក ញ៉ាន់ ប៊ុនណារិទ្ធ

៣- លោក ឃិន ណាត ៤- លោកស្រី ជិននី មុនីរស្មី

៥- លោកស្រី គុណ ពុធីតា

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១- លោក ប្រាក់ វុទ្ធី ២- លោក ជួប សោភ័ណ

៣- លោក វ៉ាន់ សារ៉ាត ៤- លោកស្រី សុខ សុជាមុនី

៥- លោក ហង់ រស្មី

នរោត្តមសីហមុនី

៣៧ល. ២៦០១. ១៦៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ចំពោះ

លោកស្រី ចំរើន មុទិតា

នរោត្តមសីហមុនី

ពាលៈ ២៦០១.១៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/៧៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសបញ្ជាប់**

**មាត្រា ១ :** ដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោកស្រី **ហួច នីតា** ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ១ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦។

**មាត្រា ២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

ពារាម. ២៦០១.១៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ២៧ *ខែមករា ឆ្នាំ២០២៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៅក្រសួងព័ត៌មាន ដល់មន្ត្រីរាជការ **០៥ រូប៖**

| | |
|---|---|
| ១-លោកជំទាវ **ឆេស ផល្លីន** | អត្តលេខ **២៩១១២០០០៩៣** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ២ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន |
| ២-ឯកឧត្តម **ផុស សុវណ្ណា** | អត្តលេខ **១៧០១២០០១៥៦** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ |

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

៣- លោកជំទាវ **ឈឹមពៅ សុភាន់ឌី** អត្តលេខ **២៧០១០០០០០២** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយិកា នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា

៤- ឯកឧត្តម **ឃឹម ចុន្ធី** អត្តលេខ **១៨០១៤០០២៤៣** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ២ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

៥- លោកជំទាវ **សុខមុំ និមល** អត្តលេខ **២៨១១២០០០៥២** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយិកា នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពារល. ២៦០១.១៧១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈដល់ឯកឧត្តម **ស គន្ធា** ជាទីប្រឹក្សាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានឋានៈស្មើអគ្គនាយក។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរសីហមុនី

ពារល. ២៦០១.១៧២

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/១១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គភាពនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងលោកជំទាវ **គីម ណេង** ជាទីប្រឹក្សាក្រសួងបរិស្ថាន ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរល.២៦០១.១៧៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ឹង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈដល់លោក **ធន់ ផុន** ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ៥ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។

**មាត្រា ២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត.០១២៦.១៥១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ឹខ ថូវ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

**នស/រកត/០១២៦/១៧៧**

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១២៩ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ដំឡើងនិងតែងតាំង ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ពីសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មកជា អនុប្រធានទី៣ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពារល. ២៦០១.១៥២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានបម្រុងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

**នស/រកត/០១២៦/១៧២៨**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

ឯកឧត្តម ស្តេហ្វាន់ ម៉េស៊ើរ៉េ ( Stefan MESSERER )
ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់
ប្រចាំព្រះរាជាណាចក្រកម្ពុជា។

*ពរល. ២៦០១. ១៨៣*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

នស/រកត/០១២៦/១៧៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

លោក កុយ សារិទ្ធ

នរោត្តមសីហមុនី

ចារ.ម. ២៦០១. ១៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៦

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/១៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ៨រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកស្រី អាត សុខុន ២- លោក ឃៀង សុមុនី

៣- លោក ហេង ជូនីន

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោក ថេង ជាង

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

លោក សូ ធីដា

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

លោក សឿន សុកក្តិ

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១- ឯកឧត្តម ទុំ សោភ័ណ ២- ឯកឧត្តម លឹម ស៊ីណាត

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា

បានជម្រាបជូនគោរពតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៩ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២២/០០៤ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៥/០២៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងដើម្បីឱ្យមានឯកសណ្ឋានភាព ការលើកទឹកចិត្ត និងពង្រឹងការទទួលខុសត្រូវក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការដែលបម្រើការងារនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា៣ .-**

ឯកសណ្ឋានរបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានដូចខាងក្រោម៖

១- សម្លៀកបំពាក់(អាវ ខោឬសំពត់)

២- មួក

៣- ខ្សែក្រវាត់និងស្បែកជើង។

**មាត្រា៤ .-**

សម្លៀកបំពាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

**ក- ចំពោះបុរស**

១- អាវពណ៌កាគី បែងចែកជា៣(បី)ប្រភេទ រួមមានអាវកឌុបដៃវែង អាវកឌុបដៃខ្លី និងអាវកតាំងដៃវែង ត្រូវបានកំណត់ដូចខាងក្រោម៖

១.១- អាវកឌុបដៃវែង មានហោប៉ៅ២(ពីរ)គ្របចន្ទល់កណ្តាល ប៉ូស្មាសងខាង ដាក់ឡេវថ្លាលើខ្លួនចំនួន៥(ប្រាំ)គ្រាប់។

១.២- អាវកឌុបដៃខ្លី មានហោប៉ៅ២(ពីរ)គ្របចន្ទល់កណ្តាល ប៉ូស្មាសងខាង ដាក់ឡេវថ្លាលើខ្លួនចំនួន៥(ប្រាំ)គ្រាប់។

១.៣- អាវកតាំងដៃវែង មានហោប៉ៅ៤(បួន)គ្របចន្ទល់កណ្ដាល ប៉ុស្ដាសងខាង ដាក់ឡេវកិបដែក លើខ្លួនចំនួន៥(ប្រាំ)គ្រាប់ ដាក់ខ្សែរូតនៅខាងមុខ ខ្សែរឹតចង្កេះខាងក្នុង និងផ្នែកខាងក្រោយខ្នងមានជីបក្លី៣(បី)ដាក់សំណាញ់ខ្យល់និងប៉ានចង្កេះ។

២- ខោជើងវែងពណ៌ខ្មៅ ខាងមុខដេរជីបក្លីម្ខាងចំនួន២(ពីរ) និងមានហោប៉ៅចំហៀងចំនួន២(ពីរ)។

**ខ- ចំពោះនារី**

១- អាវពណ៌កាគី បែងចែកជា៣(បី)ប្រភេទ រួមមានអាវកឱបដៃវែង អាវកឱបដៃខ្លី និងអាវកតាំងដៃវែង ត្រូវបានកំណត់ទម្រង់ដូចអាវរបស់បុរស។

២- ខោជើងវែងពណ៌ខ្មៅ ខាងមុខដេរជីបក្លីម្ខាងចំនួន១(មួយ) និងមានហោប៉ៅចំហៀងចំនួន២(ពីរ)។

៣- សំពត់បត់ពណ៌ខ្មៅ គ្របក្បាលជង្គង់ ឆែកខាងក្រោយចំកណ្ដាល។

**មាត្រា៥ .-**

មួក រួមមានមួកឆត្រនិងមួកកាស្កេត។

មួកឆត្រមានពណ៌កាគីដូចពណ៌អាវ មានខ្សែភ្ជាប់មកខាងក្រោមចង្កា ដោយប្រើរូតសម្រាប់បន្ដឹង ដែលត្រូវបានកំណត់សម្រាប់ប្រើប្រាស់ទាំងថ្នាក់ដឹកនាំក្រសួងនិងមន្ត្រីគ្រប់ថ្នាក់។

មួកកាស្កេតមានពណ៌កាគីដូចពណ៌អាវ ដែលផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះសង្ការពណ៌មាស មានកម្ពស់៧៨(ចិតសិបប្រាំបី)មិល្លីម៉ែត្រ និងទទឹង៦៨(ហុកសិបប្រាំបី)មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ការនេះមានកណ្ដាប់វល្លធ្វើពីក្រណាត់ឡែនពណ៌ខៀវចាស់និងមានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងនៃខ្សែធ្នាក់វេញនេះមានភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស។ ក្បាំងមួកមានពណ៌ខ្មៅ ផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ផ្កាវិដ្ឋលពណ៌មាសឬគ្មានផ្កាវិដ្ឋលពណ៌មាស អាស្រ័យតាមតួនាទី និងមានប៉ាក់ក្បាច់ភ្ញីទេសទម្រង់ស្នែងក្របីដែល មានចំនួននិងទំហំ អាស្រ័យតាមតួនាទី។ គែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ខ្សែឆ្នូតពណ៌មាស ឬក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល អាស្រ័យតាមតួនាទី ដោយត្រូវបានរៀបចំសម្រាប់សម្គាល់ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីតាមតួនាទី ដូចខាងក្រោម៖

**១- រដ្ឋមន្ត្រី**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន៣(បី) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ តម្រៀបជារាងត្រីកោណ អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន១០(ដប់)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**២- រដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ តម្រៀបជាជួររាងតជាប់គ្នា អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន១០(ដប់)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៣- អនុរដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន១០(ដប់)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៤- អគ្គលេខាធិការ អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន៣(បី) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ តម្រៀបជារាងត្រីកោណ អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៥- អគ្គលេខាធិការរង អគ្គនាយករង ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ តម្រៀបជាជួររាងតជាប់គ្នា អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៦- ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ) មិល្លីម៉ែត្រ អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៧- អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន៣(បី) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់) មិល្លីម៉ែត្រ តម្រៀបជាជួររាងតជាប់គ្នា អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៨- ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់) មិល្លីម៉ែត្រ តម្រៀបជាជួររាងតជាប់គ្នា អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**៩- អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក មានប៉ាក់ផ្កាវិដ្ឋលពណ៌មាសចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់) មិល្លីម៉ែត្រ អមដោយប៉ាក់ក្បាច់ភ្ញីទេសចំនួន៦(ប្រាំមួយ)សន្លឹកមានទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**១០- មន្ត្រី**

មួកកាស្កេត មានកំណត់សម្គាល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ ដែលផ្នែកខាងមុខនៃក្បាំងមួក គ្មានប៉ាក់ផ្កាវិដ្ឋលពណ៌មាស និងគ្មានប៉ាក់ក្បាច់ភ្ញីទេសទម្រង់ស្នែងក្របី និងគែមរបស់ក្បាំងមួក មានរឹមលម្អដោយប៉ាក់ក្បាច់គ្រាប់ស្រូវផ្កាវិដ្ឋល។

**មាត្រា៦ .-**

ខ្សែក្រវាត់និងស្បែកជើង ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ចំពោះបុរស**

- ខ្សែក្រវាត់ពណ៌ខ្មៅ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ។

**២- ចំពោះនារី**

- ខ្សែក្រវាត់ពណ៌ខ្មៅ
- ស្បែកជើងពណ៌ខ្មៅ។

**មាត្រា៧ .-**

គំរូសម្លៀកបំពាក់និងមួករបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៨ .-**

សញ្ញាសម្គាល់របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ដូចខាងក្រោម៖

១- រូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ប៉ាក់ភ្ជាប់នៅផ្នែកក្រោមស្មាដៃអាវខាងស្តាំ គម្លាតប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រពីថ្នេរស្មាអាវ ធ្វើឡើងពីក្រណាត់ប៉ាក់រាងចតុកោណកែង ដែលមានបណ្តោយប្រវែង៧៥(ចិតសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៤៨(សែសិបប្រាំបី)មិល្លីម៉ែត្រ។

២- រូបសញ្ញាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប៉ាក់ភ្ជាប់នៅចំកណ្តាលផ្នែកខាងលើហោប៉ៅអាវខាងឆ្វេង គម្លាតប្រវែង១០(ដប់)មិល្លីម៉ែត្រពីថ្នេរគម្របហោប៉ៅ និងប៉ាក់ភ្ជាប់លើមួកធត្រនៅផ្នែកខាងមុខ ធ្វើឡើងពីក្រណាត់រាងរង្វង់មូល មានអង្កត់ផ្ចិតប្រវែង៧០(ចិតសិប)មិល្លីម៉ែត្រ។

៣- ស្លាកឈ្មោះប៉ាក់ភ្ជាប់ផ្នែកខាងលើគម្របហោប៉ៅអាវស្តាំ គម្លាតប្រវែង១០(ដប់)មិល្លីម៉ែត្រពីថ្នេរគម្របហោប៉ៅ ធ្វើឡើងពីក្រណាត់ពណ៌កាគីរាងចតុកោណកែង ដែលមានបណ្តោយស្មើនឹងទំហំនៃហោប៉ៅអាវ និងទទឹងប្រវែង២០(ម្ភៃ)មិល្លីម៉ែត្រ មានរចនាស៊ុមធ្មេញជុំវិញមានពណ៌ខៀវ ផ្នែកខាងក្នុងមានប៉ាក់ឈ្មោះមន្ត្រីរាជការ ជាពុម្ពអក្សរយូនីកូដខ្មែរអូរអេសមូលឡាយពណ៌ខៀវ។

៤- សញ្ញាសម្គាល់តួនាទី ធ្វើឡើងពីលោហធាតុពណ៌មាស ដោយរចនាជាទម្រង់ជាផ្ការំដួលកំពុងរីក សម្រាប់បំពាក់នៅចំផ្នែកខាងលើហោប៉ៅអាវស្តាំ ដោយពាក់តាមតួនាទីដូចខាងក្រោម៖

ក- អគ្គលេខាធិការ អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្ការំដួលធំចំនួន៣(បី) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ)មិល្លីម៉ែត្រ និងត្រូវតម្រៀបជារាងត្រីកោណ។

ខ- អគ្គលេខាធិការរង អគ្គនាយករង ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្ការំដួលធំចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតប្រវែង១៧(ដប់ប្រាំពីរ)មិល្លីម៉ែត្រ និងត្រូវតម្រៀបជាជួររាងតជាប់គ្នា។

គ- ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្ការំដួលធំចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតម្រវែង១៧(ដប់ប្រាំពីរ)មិល្លីម៉ែត្រ។

ឃ- អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្កាវិជ្ជលតូចចំនួន៣(បី) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់)មិល្លីម៉ែត្រ និងត្រូវតម្រៀបជួរជារាងតជាប់គ្នា។

ង- ប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្កាវិជ្ជលតូចចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់)មិល្លីម៉ែត្រ និងត្រូវតម្រៀបជាជួររាងតជាប់គ្នា។

ច- អនុប្រធានការិយាល័យថ្នាក់កណ្ដាល អនុប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល ប្រើផ្កាវិជ្ជលតូចចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតប្រវែង១០(ដប់)មិល្លីម៉ែត្រ។

៥- សញ្ញាសម្គាល់សម្រាប់ពាក់បន្ថែកជាមួយខ្សែក្រោមគម្របហោប៉ៅអាវខាងស្ដាំ របស់មន្ត្រីរាជការនៃអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បំពេញបេសកកម្មស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើស។ សញ្ញាសម្គាល់នេះមានផ្នែកខាងលើរាងស្រួច និងផ្នែកខាងក្រោមមានរាងជារង្វង់មូល ដែលធ្វើពីស្បែកពណ៌បៃតងចាស់ភ្ជាប់ជាមួយតួលោហធាតុរាងរង្វង់ ដែលមានអង្កត់ផ្ចិតប្រវែង៤៥(សែសិបប្រាំ)មិល្លីម៉ែត្រ ដោយផ្ទៃខាងក្នុងមានអង្កត់ផ្ចិត៤០(សែសិប)មិល្លីម៉ែត្រ មានរំលេចសញ្ញាសម្គាល់រួមមាន៖

ក- សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជារូបសញ្ញារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ដូចខាងក្រោម៖

- **សណ្ឋានរូបផ្នែកខាងក្រៅ**
  - កម្រងបួពណ៌ក្រហមនិងខៀវ មានទម្រង់ដូចទង់ជាតិខ្មែរ ដោយផ្ទៃខាងក្នុងមានរំលេចអក្សរ «**កសក**»ពណ៌ស ជាតំណាងឱ្យឈ្មោះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - កម្រងកួរស្រូវ ពោត និងផ្កាកប្បាស អមសងខាងជារង្វង់រាងស្នែងក្របី ដែលមានពណ៌ចម្រុះលាយពណ៌មាស រុំព័ទ្ធដោយបួពណ៌ក្រហមនិងខៀវជាបីជុំ ជួបគ្នាខាងចុង ដោយមានប្រាសាទអង្គរវត្តកំពូលបីពណ៌សនៅចំកណ្ដាល ជាតំណាងឱ្យវិស័យកសិកម្មសម្រាប់ទ្រទ្រង់សន្តិសុខស្បៀងសម្រាប់ប្រជាជននិងប្រជាជាតិកម្ពុជា
  - នៅក្រោមអក្សរ «**កសក**» មានស្លឹកធ្មេញប្រាំពីរពណ៌មាស ជាតំណាងឱ្យយន្តការអនុវត្តវិស័យកសិកម្មប្រកបដោយភាពរីកចម្រើន។
- **សណ្ឋានរូបផ្នែកខាងក្នុង**
  - នៅខាងលើអក្សរ «**កសក**» មានរាងអក្សរអេធំ(A) ពណ៌ពងមាន់ ជាតំណាងឱ្យវិស័យកសិកម្ម «**Agriculture**» សំណង់សិល្បការ្យនិងប្រព័ន្ធស្រោចស្រព
  - ផ្ទៃក្នុងចំកណ្ដាល មានរូបសញ្ញារោងចក្រពណ៌ពងមាន់ កំពុងបញ្ចេញសកម្មភាព ជាតំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្ម ផ្ដល់វត្ថុធាតុដើមឱ្យរោងចក្រគ្រប់ពេល ដើម្បីផលិតចេញនូវផលិតផលបម្រើដល់សេចក្ដីត្រូវការសង្គមនិងសម្រាប់ការនាំចេញ
  - ផ្ទៃក្នុងផ្នែកខាងក្រោម មានវាលស្រែពណ៌បៃតងខ្ចី មានប្រព័ន្ធស្រោចស្រពទឹក ជាតំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្មលើដំណាំដាំដុះគ្រប់ប្រភេទ
  - ផ្ទៃក្នុងផ្នែកខាងលើ មានពណ៌ផ្ទៃមេឃ ចែកជាប្រាំចំណែក ទីមួយរូបត្រាក់ទ័រ ទីពីររូបគោ ជ្រូក មាន់ ទីបីរូបឧបករណ៍កែវស្ទង់ ទីបួនរូបត្រី ទីប្រាំរូបដើមឈើ ជាតំណាងឱ្យភាពរីកចម្រើនលើវិស័យគ្រឿងយន្តកសិកម្ម ផលិតកម្មសត្វ វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ បច្ចេកទេសវិទ្យាសាស្ត្រ និងបរិស្ថានធម្មជាតិ។

ខ- សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចក្សេត្រសាស្ត្រ ដែលរួមមានមន្ត្រីត្រួតពិនិត្យកូតតាមអនាម័យ ភ្នាក់ងារអធិការកិច្ចពូជដំណាំ និងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវប្រើប្រាស់រូបសញ្ញាអគ្គនាយកដ្ឋានក្សេត្រសាស្ត្រ។ រូបសញ្ញាអគ្គនាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវបានកំណត់ដូចខាងក្រោមៈ

- **សណ្ឋានរូបផ្នែកខាងក្រៅ**

- ធ្នូរង្វង់ផ្នែកខាងឆ្វេងនិងខាងស្តាំ រចនាដោយកួរស្រូវពណ៌មាស ជាតំណាងឱ្យផលិតផលស្បៀង ដែលមានដំណាំស្រូវជាមូលដ្ឋាន និងជាមរតកកសិកម្មកម្ពុជាតាំងពីសម័យអង្គរ
- ធ្នូរង្វង់ផ្នែកខាងក្រោម រចនាដោយកងចក្រពណ៌មាស ជាតំណាងឱ្យគ្រឿងយន្តនិងឧបករណ៍កសិកម្ម និងការធ្វើទំនើបកម្មផលិតកម្មដំណាំ
- នៅផ្នែកខាងលើកងចក្រ រចនាដោយកម្រងបូមានសណ្ឋាននិងពណ៌ដូចទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាតំណាងឱ្យឯកសារគោលនយោបាយ ច្បាប់ បទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានា
- នៅពីលើបូ មានប៉ាក់អក្សរពុម្ពពណ៌ស «**អ ឆ ក**» ជាតំណាងឱ្យអគ្គនាយកដ្ឋានក្សេត្រសាស្ត្រ។

- **សណ្ឋានរូបផ្នែកខាងក្នុង**

- ផ្នែកខាងលើ រំលេចដោយរូបភាពផ្ទៃមេឃពណ៌ខៀវនិងពពកពណ៌ស ជាតំណាងឱ្យខ្យល់អាកាស និងពន្លឺព្រះអាទិត្យសម្រាប់ឱ្យរុក្ខជាតិធ្វើរស្មីសំយោគ ដើម្បីជំរុញការលូតលាស់និងផ្តល់ផ្កាផ្លែ
- នៅចំកណ្តាលរង្វង់ មានរូបដៃទ្រុក្ខជាតិ ជាតំណាងឱ្យធនធានមនុស្សដែលខិតខំអភិវឌ្ឍនិងអនុវត្តបច្ចេកទេសដាំដុះ ថែទាំ និងការពារដំណាំឱ្យទទួលភោគផលល្អ
- នៅចន្លោះកណ្តាលរូបដៃទាំងពីរ មានដើមរុក្ខជាតិកំពុងដុះលូតលាស់ល្អ ជាតំណាងឱ្យមុខដំណាំគ្រប់ប្រភេទនៃអនុវិស័យដំណាំកម្ពុជា
- នៅផ្នែកកណ្តាលខាងក្រោមរូបដៃនិងដើមរុក្ខជាតិ រំលេចដោយផ្ទៃវាលពណ៌បៃតង ជាតំណាងឱ្យដីស្រែ ចម្ការ ច្បារដំណាំគ្រប់ប្រភេទ នៃអនុវិស័យដំណាំ
- នៅផ្នែកខាងឆ្វេង មានធ្នូចំណិតរង្វង់ពណ៌ខៀវ ជាតំណាងឱ្យធនធានទឹកសម្រាប់ស្រោចស្រពដំណាំ រីឯនៅផ្នែកខាងស្តាំ មានធ្នូចំណិតរង្វង់ពណ៌ត្នោត ជាតំណាងឱ្យផ្ទៃធរណីដែលមានជីជាតិសម្រាប់បង្កបង្កើនផល។

គ- សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ គឺជារូបសញ្ញារបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានកំណត់ដូចខាងក្រោមៈ

- មានរាងជារង្វង់ផ្ទៃពណ៌មាស ដែលមានរំលេចរូបមែកឈើមានស្លឹកបី ជានិមិត្តរូបដំណាំចំណីសត្វ និងមានរូបសត្វទាំងប្រាំបួន ស្ថិតក្នុងផ្ទៃពណ៌បៃតង ពណ៌ផ្ទៃមេឃ ជានិមិត្តរូបផលិតកម្មសត្វ វាលស្មៅ ការចិញ្ចឹមសត្វ និងសក្តានុពលនៃការអភិវឌ្ឍការចិញ្ចឹមសត្វ រីឯផ្នែកខាងក្រោម មានរូបបូពណ៌ក្រហមនិងខៀវដាក់ពាសនៅលើរង្វង់ផ្ទៃពណ៌មាស និងមានរំលេចតួអក្សរ«**អ ស ផ ស**» ជាតំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- នៅចំកណ្តាលនៃផ្ទៃរង្វង់ មានៈ
  - ផ្ទាំងពណ៌ទឹកប៊ិកបីជ្រុង ជានិមិត្តរូបចំណងទាក់ទងរវាងសត្វ ភ្នាក់ងារចម្លងជំងឺ និងបរិស្ថាន រីឯអក្សរវីធំ«V»ពណ៌មាស ជានិមិត្តរូបបសុពេទ្យ

- រូបពស់ពណ៌មាស ជានិមិត្តរូបបសុឱសថ និងរូបម្ជុលពណ៌មាសដែលពស់រុំព័ទ្ធ ជានិមិត្តរូបការការពារនិងព្យាបាលសត្វ
- ផ្ទៃពណ៌ទឹកមាសនៅក្នុងរង្វង់មូលដែលព័ទ្ធជុំវិញផ្ទៃពណ៌ទឹកប៊ិក ជានិមិត្តរូបចំណូលគ្រួសារនិងសេដ្ឋកិច្ចជាតិ។

ឃ- សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចព្រៃឈើនិងសត្វព្រៃ គឺជារូបសញ្ញារបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ ត្រូវបានកំណត់ដូចខាងក្រោម៖

- វណ្ឌខាងក្រៅផ្នែកខាងលើ មានក្បាច់ភ្ញីទេសពណ៌មាសផុសឡើងអមសងខាងតួមកុដពណ៌មាសចម្រុះដោយពណ៌ក្រហមក្រមៅ ហើយផ្ទត់សំពត់មានពណ៌មាសចម្រុះដោយពណ៌ក្រហមក្រមៅទ្រមកុដ
- វណ្ឌខាងក្រៅផ្នែកខាងក្រោម មានពណ៌បៃតងចាស់រំលេចដោយតួអក្សរ **«អ ន ព»** ពណ៌មាសជាតំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ
- វណ្ឌខាងក្រៅទាំងសងខាងក្រណាត់បូ មានផ្ទត់បីថ្នាក់ពណ៌ក្រហមក្រមៅ និងចុងជាយនីមួយៗរំលេចពណ៌មាស
- នៅចំកណ្ដាលនៃសញ្ញាសម្គាល់ មានដើមឈើពណ៌មាសនិងកន្សោមស្លឹកបីត្រសុំពណ៌បៃតងចាស់ និងនៅប៉ែកខាងគល់ដើមឈើ មានរូបញញួរត្រាអគ្គនាយកដ្ឋានព្រៃឈើនិងសត្វព្រៃ ចំនួនពីរដាក់ខ្វែងគ្នាជាប់នឹងដើមឈើ
- នៅសងខាងនិងខាងក្រោមដើមឈើកណ្ដាលនៃសញ្ញាសម្គាល់ មានផ្កាចន្ទន៍បែកជារង្វង់ក្បាច់ភ្ញីស្លឹកកន្ទួតពណ៌មាសពីរ មានទម្រង់ជាស្នែងក្របី។

ង- សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចជលផល គឺជាសញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានជលផលត្រូវបានកំណត់ដូចខាងក្រោម៖

- ខាងលើមានកន្ទុយនាគរាជពីរព័ទ្ធគ្នាជាក្បាច់ភ្ញីពណ៌មាស
- ខាងក្រោមមានផ្ទៃពណ៌ក្រហម និងផ្នែកចុងសងខាងមានពីរផ្ទត់រំលេចដោយតួអក្សរ **«អ ន ជ»** ពណ៌ស ជាតំណាងឱ្យឈ្មោះរបស់អគ្គនាយកដ្ឋានជលផល
- ផ្នែកសងខាងមានខ្លួននិងក្បាលនាគរាជចំនួនពីរពណ៌មាសបែរមុខចេញក្រៅ
- ផ្នែកលើមានពណ៌ផ្ទៃមេឃរំលេចទៅដោយរូបត្រីចំនួនពីរពណ៌ស និងរូបបង្កងមួយក្បាលពណ៌មាសនៅចំកណ្ដាល
- ផ្នែកកណ្ដាលមានព្រៃលិចទឹកនិងព្រៃកោងកាងមានពណ៌បៃតងខ្ចី
- ផ្នែកក្រោមមានរូបទឹករលកចំនួនប្រាំពីរពណ៌ខៀវទឹកប៊ិក ព័ទ្ធដោយទឹកសមុទ្រពណ៌ផ្ទៃមេឃដែលរំលេចដោយជាយពណ៌ស។

ច- សញ្ញាសម្គាល់ផ្សេងទៀតដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៩ .-**

គំរូសញ្ញាសម្គាល់របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា១០ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវទាំងសងខាង ត្រូវកំណត់ទម្រង់រួមដូចខាងក្រោម៖

- ធ្វើឡើងពីក្រណាត់កម្ទីពណ៌ខៀវចាស់ មានរាងទ្រវែងស្តួច ខាងចុងមានរាងកោងជាមុំទាល ដោយមានទំហំស្របតាមការរចនាទៅតាមលំដាប់ឋានន្តរសក្តិនិងថ្នាក់
- រចនាដោយប៉ាក់ស៊ុមព័ទ្ធជុំវិញ និងផ្ទៃខាងក្នុងមានរំលេចរូបសញ្ញារូបព្រះសង្ការពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦(ដប់ប្រាំមួយ)មិល្លីម៉ែត្រ និងមានរូបសញ្ញាមកុដរាជ្យនិងព្រះខ័នរាជ្យពណ៌មាសទំហំ២៥(ម្ភៃប្រាំ)មិល្លីម៉ែត្រ គុណនឹង១៦(ដប់ប្រាំមួយ)មិល្លីម៉ែត្រ
- ផ្ទៃខាងក្នុងនៅផ្នែកខាងក្រោមចំពីលើគល់ស៊ុម មានផ្ទៃប៉ាក់ពណ៌មាសទំហំទទឹងប្រវែង១៥(ដប់ប្រាំ)មិល្លីម៉ែត្រ ដោយមានរំលេចអក្សរ «**ក ស ក**» ជាតំណាងឱ្យឈ្មោះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានឆ្នូតក្បាច់ធ្មេញត្រីភ្ជាប់ផ្នែកខាងលើនិងខាងក្រោមកម្រាស់៣(បី)មិល្លីម៉ែត្រ។

សញ្ញាសក្តិនេះ ត្រូវបានកំណត់ជាសម្គាល់សម្រាប់ថ្នាក់ដឹកនាំក្រសួង និងទៅតាមលំដាប់ឋានន្តរសក្តិ និងការបែងចែកជាថ្នាក់ក្នុងក្របខ័ណ្ឌនីមួយៗនៃមន្ត្រី។

**មាត្រា១១ .-**

សញ្ញាសក្តិសម្រាប់ថ្នាក់ដឹកនាំក្រសួង មានទម្រង់រួមដូចបានកំណត់ក្នុងមាត្រា១០នៃអនុក្រឹត្យនេះ និងត្រូវបានរចនានិងមានកំណត់សម្គាល់ដូចខាងក្រោម៖

**១- សញ្ញាសក្តិសម្រាប់រដ្ឋមន្ត្រី**

- បណ្តោយមានប្រវែង១៣៦(មួយរយសាមសិបប្រាំមួយ)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៩(សែសិបប្រាំបួន)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន៣(បី)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជួលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ផ្ទៃខាងក្នុងមានរំលេចរូបសញ្ញាផ្កាវិជ្ជួលពណ៌មាសចំនួន៣(បី) ដែលមានអង្កត់ផ្ចិតទំហំ២០(ម្ភៃ)មិល្លីម៉ែត្រ តម្រៀបជារាងត្រីកោណ។

**២- សញ្ញាសក្តិសម្រាប់រដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧(ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន២(ពីរ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជួលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ផ្ទៃខាងក្នុងមានរំលេចរូបសញ្ញាផ្កាវិជ្ជួលពណ៌មាសចំនួន២(ពីរ) ដែលមានអង្កត់ផ្ចិតទំហំ២០(ម្ភៃ)មិល្លីម៉ែត្រ តម្រៀបជារាងជួរស្មើគ្នា។

**៣- សញ្ញាសក្តិសម្រាប់អនុរដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤(ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល

- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ផ្ទៃខាងក្នុងមានរំលេចរូបសញ្ញាផ្កាវិជ្ជលពណ៌មាសចំនួន១(មួយ) ដែលមានអង្កត់ផ្ចិតទំហំ២០(ម្ភៃ) មិល្លីម៉ែត្រ។

**មាត្រា១២.-**

សញ្ញាសក្តិសម្រាប់មន្ត្រីក្នុងក្របខ័ណ្ឌប្រភេទ **ក** មានទម្រង់រួមដូចបានកំណត់ក្នុងមាត្រា១០នៃអនុក្រឹត្យនេះ ដោយផ្ទៃខាងក្នុងមានរំលេចរូបសញ្ញាក្តួរស្រូវផ្កាវិជ្ជលពណ៌មាសដែលមានបណ្តោយប្រវែង២៥(ម្ភៃប្រាំ) មិល្លីម៉ែត្រ និងទទឹងប្រវែង១០(ដប់)មិល្លីម៉ែត្រ តម្រៀបជារាងបញ្ឈរ។

សញ្ញាសក្តិដូចបានកំណត់ក្នុងកថាខណ្ឌខាងលើនេះ ត្រូវបានរចនានិងមានកំណត់សម្គាល់ដូចខាងក្រោម៖

**ក- ឋានន្តរសក្តិទី១**

**១- ឋានន្តរសក្តិ ក.១.១**

- បណ្តោយមានប្រវែង១៣៦(មួយរយសាមសិបប្រាំមួយ)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៩(សែសិបប្រាំបួន)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន៣(បី)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្តួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្តួរ។

**២- ឋានន្តរសក្តិ ក.១.២**

- បណ្តោយមានប្រវែង១៣៦(មួយរយសាមសិបប្រាំមួយ)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៩(សែសិបប្រាំបួន)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន២(ពីរ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានស៊ុមព័ទ្ធជុំវិញខាងក្នុងជាប្រភេទខ្សែឆ្នូតពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ) មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្តួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្តួរ។

**៣- ឋានន្តរសក្តិ ក.១.៣**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧(ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន២(ពីរ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្តួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្តួរ។

**៤- ឋានន្តរសក្តិ ក.១.៤**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧(ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល

- ស៊ុមព័ទ្ធជុំវិញខាងក្រៅមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានស៊ុមព័ទ្ធជុំវិញខាងក្នុងជាប្រភេទខ្សែធ្នូត ពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាង ដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្បួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្បួរ។

**៥- ឋានន្តរសក្តិ ក.១.៥**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤ (ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាសដែលមាន ទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង ១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្បួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្បួរ។

**៦- ឋានន្តរសក្តិ ក.១.៦**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤ (ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែធ្នូតពណ៌មាសដែលមានទទឹងប្រវែង៣(បី) មិល្លីម៉ែត្រអមដោយខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្បួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន៣(បី)ក្បួរ។

**ខ- ឋានន្តរសក្តិទី២**

**១- ឋានន្តរសក្តិ ក.២.១**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧ (ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោង ជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន២(ពីរ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលជុំនីមួយៗ មានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹង ប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្បួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន២(ពីរ)ក្បួរ។

**២- ឋានន្តរសក្តិ ក.២.២**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧ (ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោង ជាមុំទាល
- ស៊ុមព័ទ្ធជុំវិញខាងក្រៅមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌ មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានស៊ុមព័ទ្ធជុំវិញខាងក្នុងជាប្រភេទខ្សែធ្នូត ពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាង ដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្បួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន២(ពីរ)ក្បួរ។

**៣- ឋានន្តរសក្តិ ក.២.៣**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤ (ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្ករស្រូវផ្កាវិជ្ជលពណ៌មាសចំនួន២(ពីរ)ក្ករ។

**៤- ឋានន្តរសក្តិ ក.២.៤**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤ (ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែឆ្នូតពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ) មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្ករស្រូវផ្កាវិជ្ជលពណ៌មាសចំនួន២(ពីរ)ក្ករ។

**គ- ឋានន្តរសក្តិទី៣**

**១- ឋានន្តរសក្តិ ក.៣.១**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧ (ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន២(ពីរ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាស ដែលជុំនីមួយៗមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្ករស្រូវផ្កាវិជ្ជលពណ៌មាសចំនួន១(មួយ)ក្ករ។

**២- ឋានន្តរសក្តិ ក.៣.២**

- បណ្តោយមានប្រវែង១៣៣(មួយរយសាមសិបបី)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៧ (ហាសិបប្រាំពីរ)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៦(សែសិបប្រាំមួយ)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញខាងក្រៅមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានស៊ុមព័ទ្ធជុំវិញខាងក្នុងជាប្រភេទខ្សែឆ្នូតពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្ករស្រូវផ្កាវិជ្ជលពណ៌មាសចំនួន១(មួយ)ក្ករ។

**៣- ឋានន្តរសក្តិ ក.៣.៣**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤ (ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល

- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែគ្រាប់ស្រូវផ្កាវិជ្ជលពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ និងមានខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្អួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន១(មួយ)ក្អួរ។

**៤- ឋានន្តរសក្តិ ក.៣.៤**

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤(ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែធ្នូតពណ៌មាសដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌មាសអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ប្រើរូបសញ្ញាក្អួរស្រូវផ្កាវិជ្ជលពណ៌មាសចំនួន១(មួយ)ក្អួរ។

**មាត្រា១៣ .-**

សញ្ញាសក្តិសម្រាប់មន្ត្រីក្នុងក្របខ័ណ្ឌប្រភេទ **ខ** មានទម្រង់រួមដូចបានកំណត់ក្នុងមាត្រា១០នៃអនុក្រឹត្យនេះ និងត្រូវកំណត់តាមឋានន្តរសក្តិដូចមន្ត្រីក្នុងក្របខ័ណ្ឌប្រភេទ **ក** ដែលមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ ដោយមានការរចនានិងការរំលេចគ្រប់រូបសញ្ញាលើសញ្ញាសក្តិ ត្រូវប្រើពណ៌ប្រាក់។

**មាត្រា១៤ .-**

សញ្ញាសក្តិសម្រាប់មន្ត្រីក្នុងក្របខ័ណ្ឌប្រភេទ **គ** មានទម្រង់រួមដូចបានកំណត់ក្នុងមាត្រា១០នៃអនុក្រឹត្យនេះ និងត្រូវបានរចនានិងមានកំណត់សម្គាល់ដូចខាងក្រោម៖

- បណ្តោយមានប្រវែង១៣០(មួយរយសាមសិប)មិល្លីម៉ែត្រ ទំហំខាងគល់មានប្រវែង៥៤(ហាសិបបួន)មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៣(សែសិបបី)មិល្លីម៉ែត្រ មានរាងកោងជាមុំទាល
- ស៊ុមព័ទ្ធជុំវិញមានចំនួន១(មួយ)ជុំ ជាប្រភេទក្បាច់ខ្សែធ្នូតពណ៌សំរឹទ្ធដែលមានទទឹងប្រវែង៣(បី)មិល្លីម៉ែត្រ អមដោយខ្សែស៊ុមពណ៌សំរឹទ្ធអមសងខាងដែលមានទទឹងប្រវែង១(មួយ)មិល្លីម៉ែត្រ
- ផ្ទៃខាងក្នុងមានរំលេចរូបសញ្ញាក្អួរស្រូវផ្កាវិជ្ជលពណ៌សំរឹទ្ធចំនួន១(មួយ)ក្អួរ ដែលមានបណ្តោយប្រវែង២៥(ម្ភៃប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង១០(ដប់)មិល្លីម៉ែត្រ តម្រៀបជារាងបញ្ឈរ។

**មាត្រា១៥ .-**

គំរូសញ្ញាសក្តិរបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការផ្តល់និងការប្រើឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា១៦ .-**

មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានរបបឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ស្របតាមទំហំថវិកាជាតិប្រចាំឆ្នាំ ដែលវិភាជជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

**មាត្រា១៧ .-**

ក្នុងពេលចូលរួមក្នុងដំណើរការកិច្ចនីតិវិធីតុលាការ កិច្ចប្រជុំផ្លូវការ ឬពិធីផ្លូវការផ្សេងៗ មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រើគំរូឯកសណ្ឋានមានសញ្ញាសម្គាល់ សញ្ញាសក្តិ និងមួកកាស្កែត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា១៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលរួមមានការបំពេញបេសកកម្ម ការស្រាវជ្រាវ ការត្រួតពិនិត្យ ការទប់ស្កាត់ ការបង្ក្រាបបទល្មើស មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រើគំរូឯកសណ្ឋានមានសញ្ញាសម្គាល់ សញ្ញាសក្តិ និងមួកឆត្រ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

អាវកតាំងដៃវែង អាចពាក់ពីលើឯកសណ្ឋានខាងលើ តាមស្ថានភាពចាំបាច់។

**មាត្រា១៩ .-**

ក្នុងពេលបំពេញការងារប្រចាំថ្ងៃនៅការិយាល័យ មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចប្រើឯកសណ្ឋាន រួមជាមួយសញ្ញាសម្គាល់តួនាទីនិងសញ្ញាសក្តិ។ ឯកសណ្ឋាន អាចប្រើប្រាស់ដូចខាងក្រោម៖

- ចំពោះបុរស អាចស្លៀកពាក់អាវកឧបដៃវែងឬអាវកឧបដៃខ្លី ជាមួយនឹងខោជើងវែង ដោយត្រូវដាក់អាវក្នុងខោ រីឯអាវកតាំងដៃវែង អាចពាក់ពីលើអាវផ្សេងទៀតដូចពាក់អាវធំធម្មតា
- ចំពោះនារី អាចស្លៀកពាក់អាវកឧបដៃវែងឬអាវកឧបដៃខ្លី ជាមួយនឹងខោជើងវែងឬសំពត់បត់ ដោយត្រូវដាក់អាវក្នុងខោឬសំពត់ រីឯកអាវកតាំងដៃវែង អាចពាក់ពីលើអាវផ្សេងទៀតដូចពាក់អាវធំធម្មតា។

គំរូសម្លៀកបំពាក់សម្រាប់ពេលបំពេញការងារប្រចាំថ្ងៃនៅការិយាល័យ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

**មាត្រា២០ .-**

ក្នុងពេលបំពេញបេសកកម្មការងារនៅតាមបណ្តារាជធានី ខេត្ត មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចប្រើឯកសណ្ឋាន រួមជាមួយសញ្ញាសម្គាល់តួនាទី ដោយពុំចាំបាច់ប្រើសញ្ញាសក្តិ។ ឯកសណ្ឋាន អាចប្រើប្រាស់ដូចខាងក្រោម៖

- ចំពោះបុរស អាចស្លៀកពាក់អាវកឧបដៃវ ឬអាវកឧបដៃខ្លី ជាមួយនឹងខោជើងវែង រីឯអាវកតាំងដៃវែង អាចពាក់ពីលើអាវផ្សេងទៀតដូចពាក់អាវធំធម្មតា
- ចំពោះនារី អាចស្លៀកពាក់អាវកឧបដៃវែងឬអាវកឧបដៃខ្លី ជាមួយនឹងខោជើងវែង រីឯអាវកតាំងដៃវែង អាចពាក់ពីលើអាវផ្សេងទៀតដូចពាក់អាវធំធម្មតា
- អាចប្រើមួកឆត្រ តាមស្ថានភាពចាំបាច់។

គំរូសម្លៀកបំពាក់ក្នុងពេលបំពេញបេសកកម្មការងារនៅតាមបណ្តារាជធានី ខេត្ត របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា២១ .-**

ជនណាដែលស្លៀកពាក់ជាសាធារណៈ ដោយគ្មានសិទ្ធិស្លៀកពាក់នូវឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា២២ .–**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកំពុងប្រើសព្វថ្ងៃ ត្រូវបន្តប្រើរហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .–**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលកំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានមុនអនុក្រឹត្យនេះ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូសម្លៀកបំពាក់និងមួករបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ១- គំរូសម្លៀកបំពាក់

#### ក- អាវកខុបដៃវែង ដៃខ្លី និងខោជើងវែង សម្រាប់បុរស

| អាវកខុបដៃវែងនិងខោជើងវែង | ទម្រង់ពេលស្លៀកពាក់ |
|---|---|
|  |  |

| អាវកខុបដៃខ្លីនិងខោជើងវែង | ទម្រង់ពេលស្លៀកពាក់ |
|---|---|
|  |  |

## ខ- អាវកខុបដៃវែង ដៃខ្លី និងខោជើងវែងឬសំពត់បត់ សម្រាប់នារី

| អាវកខុបដៃវែងនិងខោជើងវែង | ទម្រង់ពេលស្លៀកពាក់ជាមួយខោជើងវែងឬសំពត់បត់ |
|---|---|
|  |  |

| អាវកខុបដៃខ្លីនិងខោជើងវែង | ទម្រង់ពេលស្លៀកពាក់ជាមួយខោជើងវែងឬសំពត់បត់ |
|---|---|
|  |  |

### គ- អាវកតាំងដៃវែង និងខោជើងវែង សម្រាប់បុរសនិងនារី

អាវកតាំងដៃវែងនិងខោទម្រង់ពេលស្លៀកពាក់



## ២- គំរូមួក

### ក- គំរូមួកឆត្រ



**ខ- គំរូមួកកាស្កេត**

| | | |
|---|---|---|
| ១ | រដ្ឋមន្ត្រី |  |
| ២ | រដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល |  |
| ៣ | អនុរដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល |  |
| ៤ | អគ្គលេខាធិការ អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែល |  |
| ៥ | អគ្គលេខាធិការរង អគ្គនាយករង ឬថ្នាក់ប្រហាក់ប្រហែល |  |
| ៦ | ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល |  |

| | | |
|---|---|---|
| ៧ | អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល |  |
| ៨ | ប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល |  |
| ៩ | អនុប្រធានការិយាល័យថ្នាក់កណ្ដាល អនុប្រធានការិយាល័យនៃមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែល |  |
| ១០ | មន្ត្រី |  |

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូសញ្ញាសម្គាល់របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ១- គំរូរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា

មានទម្រង់ជាចតុកោណកែង សម្រាប់ដេរប៉ាក់ភ្ជាប់តែជាមួយអាវ

៤៨(សែសិបប្រាំបី)មិល្លីម៉ែត្រ



----- ៧៥(ចិតសិបប្រាំ)មិល្លីម៉ែត្រ ---

### ២- គំរូរូបសម្គាល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មានទម្រង់ជារង្វង់មូល សម្រាប់ដេរប៉ាក់ភ្ជាប់ជាមួយអាវនិងមួក




មានអង្កត់ផ្ចិតប្រវែង៧០(ចិតសិប)មិល្លីម៉ែត្រ

### ៣- គំរូស្លាកឈ្មោះរបស់មន្ត្រី

**ឈ្មោះមន្ត្រី**

បណ្តោយប្រវែង១២០(មួយរយម្ភៃ)មិល្លីម៉ែត្រ និងទទឹងប្រវែង២០(ម្ភៃ)មិល្លីម៉ែត្រ

### ៤- គំរូសញ្ញាសម្គាល់តួនាទី

| តួនាទី | រូបសញ្ញាផ្ការំដួល |
|---|---|
| អគ្គលេខាធិការ អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែល |  |
| អគ្គលេខាធិការរង អគ្គនាយករង ឬថ្នាក់ប្រហាក់ប្រហែល |  |
| ប្រធាននាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល |  |
| អនុប្រធាននាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល |  |
| ប្រធានការិយាល័យឬថ្នាក់ប្រហាក់ប្រហែល |  |
| អនុប្រធានការិយាល័យឬថ្នាក់ប្រហាក់ប្រហែល |  |

**៥- គំរូសញ្ញាសម្គាល់ពាក់បន្ថោកជាមួយខ្សែចង្រ្កាមគម្របហោប៉ៅអាវខាងស្តាំ**

**ក- គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ច**

| | |
|---|---|
| - សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |  |
| សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចក្សេត្រសាស្ត្រ ដែលរួមមាន៖<br>- ភ្នាក់ងារអធិការកិច្ចពូជដំណាំ<br>- មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម<br>- មន្ត្រីត្រួតពិនិត្យភូតគាមអនាម័យ |  |
| - សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ |  |
| - សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចព្រៃឈើនិងសត្វព្រៃ |  |

| | |
|---|---|
| - សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចជលផល |  |

ខ- គំរូដាក់សញ្ញាសម្គាល់របស់អង្គភាពផ្សេងទៀត ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក




ពុម្ពគំរូកំណត់ទីតាំងដែលត្រូវដាក់សញ្ញាសម្គាល់របស់អង្គភាពផ្សេងទៀត
ដែលមានទំហំអង្កត់ផ្ចិតប្រវែង៤០(សែសិប)មិល្លីម៉ែត្រ

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូសញ្ញាសក្តិរបស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ១- គំរូសញ្ញាសក្តិសម្រាប់ថ្នាក់ដឹកនាំក្រសួង

| | | |
|---|---|---|
|  |  |  |
| រដ្ឋមន្ត្រី | រដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល | អនុរដ្ឋលេខាធិការឬថ្នាក់ប្រហាក់ប្រហែល |

### ២- គំរូសញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក

| ឋានន្តរសក្តិទី១ | | |
|---|---|---|
|  |  |  |
| ក.១.១ | ក.១.២ | ក.១.៣ |



ក.១.៤



ក.១.៥



ក.១.៦

ឋានន្តរសក្តិនាយ



ក.២.១



ក.២.២



ក.២.៣



ក.២.៤

| ឋានន្តរសក្តិទី៣ | | | |
|---|---|---|---|
|  |  |  |  |
| ក.៣.១ | ក.៣.២ | ក.៣.៣ | ក.៣.៤ |

៣- គំរូសញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

| ឋានន្តរសក្តិទី១ | | |
|---|---|---|
|  |  |  |
| ខ.១.១ | ខ.១.២ | ខ.១.៣ |

| | | |
|---|---|---|
|  |  |  |
| ខ.១.៤ | ខ.១.៥ | ខ.១.៦ |

**ឋានន្តរសក្តិទី២**

| | | | |
|---|---|---|---|
|  |  |  |  |
| ខ.២.១ | ខ.២.២ | ខ.២.៣ | ខ.២.៤ |

| ឋានន្តរសក្តិទី៣ | | | |
|---|---|---|---|
|  |  |  |  |
| ខ.៣.១ | ខ.៣.២ | ខ.៣.៣ | ខ.៣.៤ |

**៤- គំរូសញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ គ**




គ.១ ដល់ គ.១០

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គំរូឯកសណ្ឋានមានសញ្ញាសម្គាល់ សញ្ញាសក្តិ និងមួកកាស្កេត
# ក្នុងពេលចូលរួមក្នុងដំណើរការកិច្ចនីតិវិធីតុលាការ កិច្ចប្រជុំផ្លូវការ និងពិធីផ្លូវការផ្សេងៗ

| សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួក |
| --- |
|  |
| (១)<br>មួកកាស្កេត |
|  |
| (២)<br>រូបទង់ជាតិ |
|  |
| (៣)<br>រូបសញ្ញាក្រសួងកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ |
|  |
| (៤)<br>សញ្ញាសក្តិ |
|  |
| (៥)<br>សញ្ញាសម្គាល់តួនាទី |
|  ឈ្មោះមន្ត្រី |
| (៦)<br>ស្លាកឈ្មោះ |
|  |
| (៧)<br>សញ្ញាសម្គាល់<br>សម្រាប់ពាក់បន្តោក |



ឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គំរូឯកសណ្ឋានមានសញ្ញាសម្គាល់ សញ្ញាសក្តិ និងមួកធ្រ
# ពេលប្រតិបត្តិការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ






ឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**គំរូសម្លៀកបំពាក់សម្រាប់ពេលបំពេញការងារប្រចាំថ្ងៃនៅការិយាល័យ**

**១- ចំពោះបុរស**

| សញ្ញាសម្គាល់និងសញ្ញាសក្តិ | | | | |
|---|---|---|---|---|
|  |  |  |  |  |
| (១)<br>រូបទង់ជាតិ | (២)<br>រូបសញ្ញាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | (៣)<br>សញ្ញាសក្តិ | (៤)<br>សញ្ញាសម្គាល់តួនាទី | (៥)<br>ស្លាកឈ្មោះ |



**២- ចំពោះនារី**

| សញ្ញាសម្គាល់និងសញ្ញាសក្តិ | | | | |
|---|---|---|---|---|
| | | | | |
| (១)<br>រូបទង់ជាតិ | (២)<br>រូបសញ្ញាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | (៣)<br>សញ្ញាសក្តិ | (៤)<br>សញ្ញាសម្គាល់តួន | ស្លាកឈ្មោះ |



ឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គំរូសម្លៀកបំពាក់ក្នុងពេលបំពេញបេសកកម្មការងារនៅតាមបណ្តារាជធានី ខេត្ត

### ១- ចំពោះបុរស

| សញ្ញាសម្គាល់ | | | |
|---|---|---|---|
| | | | ឈ្មោះមន្ត្រី |
| (១) រូបទង់ជាតិ | (២) រូបសញ្ញាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | (៣) សញ្ញាសម្គាល់តួនាទី | (៤) ស្លាកឈ្មោះ |



**២- ចំពោះនារី**

| សញ្ញាសម្គាល់ | | | |
|---|---|---|---|
|  |  |  |  |
| (១) រូបទង់ជាតិ | (២) រូបសញ្ញាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | (៣) សញ្ញាសម្គាល់តួនាទី | (៤) ស្លាកឈ្មោះ |



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៨ ... អនក្រ.គគ

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនទីប្រឹក្សា និងមន្ត្រីរាជការ នៃក្រសួងកិច្ចការនារី ចំនួន ៦៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | នន់ លីណា | ទីប្រឹក្សាបច្ចេកទេស ខុទ្ទកាល័យរដ្ឋមន្ត្រី |
| ២- | លោកស្រី | ព្រាប ស្រីលក្ខិណា | អនុប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក |
| ៣- | លោកស្រី | ហ៊ូ ចិន្តា | អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |



៩៤

| | | | |
|---|---|---|---|
| ៤- | លោក | អុង សត្យាពេជ្រ | អនុប្រធានការិយាល័យសវនកម្មទី១ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៥- | លោកស្រី | ហ៊ឹម សារឿន | អនុប្រធានការិយាល័យស្ត្រី និងកិច្ចការអន្តរជាតិក្រៅតំបន់អាស៊ាន នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៦- | លោកស្រី | ប៉េង ស្រីភ័ស្ស | អនុប្រធានការិយាល័យអប់រំនិងបំណិនជីវិត នៃនាយកដ្ឋានស្ត្រី និងការអប់រំ |
| ៧- | លោកស្រី | អ៊ុក ច័ន្ទស៊ីថា | អនុប្រធានការិយាល័យអប់រំកុមារតូច នៃនាយកដ្ឋានស្ត្រីនិងការអប់រំ |
| ៨- | លោកស្រី | ប៊ូ ចំរើន | អនុប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់-ផែនការនិងស្ថិតិ នៃមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ |
| ៩- | លោកស្រី | ស៊ាង វណ្ណលក្ខិណា | ប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ចាម |
| ១០- | លោកស្រី | ហាក់ សុវណ្ណចាន់ដារី | ប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ |
| ១១- | លោក | ហា ប៊ុនឡុង | អនុប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ធំ |
| ១២- | លោកស្រី | ផុន កុសល | អនុប្រធានមន្ទីរកិច្ចការនារីខេត្តកំពត |
| ១៣- | លោកស្រី | សោម សេដ្ឋា | ប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់ នៃមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ |
| ១៤- | លោកស្រី | វ៉ាន់ ចាន់ណា | អនុប្រធានមន្ទីរកិច្ចការនារីខេត្តសៀមរាប |
| ១៥- | លោកស្រី | យ៉ឹង លាប | អនុប្រធានមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៦- | លោកស្រី | ជឹប សោភ័ណ | អនុប្រធានមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៧- | លោកស្រី | ហេង សេរីវត្តី | ប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់-ផែនការនិងស្ថិតិ នៃមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៨- | លោកស្រី | ច័ន្ទ ថារី | ប្រធានមន្ទីរកិច្ចការនារីខេត្តប៉ៃលិន |
| ១៩- | លោកស្រី | ស៊ា ផេន | ប្រធានការិយាល័យស្ត្រីនិងសុខភាព-ស្ត្រីនិងការអប់រំ នៃមន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង |
| ២០- | លោកស្រី | ជុំ សុខន | ប្រធានការិយាល័យសមភាពយេនឌ័រ និងព័ត៌មាន នៃមន្ទីរកិច្ចការនារីខេត្តកែប |
| ២១- | លោកស្រី | សែម សុភ័ក្ត | អនុប្រធានការិយាល័យបូកសរុប នៃនាយកដ្ឋានរដ្ឋបាលបុគ្គលិក |
| ២២- | លោកស្រី | ហ៊ិន កញ្ញា | មន្ត្រី នៃនាយកដ្ឋានរដ្ឋបាលបុគ្គលិក។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ប៊ិន ចាន់ដារ៉ា | អនុប្រធានការិយាល័យបូកសរុប នៃនាយកដ្ឋានរដ្ឋបាលបុគ្គលិក |
| ២- | លោក | ភួង វុទ្ធា | មន្ត្រី នៃនាយកដ្ឋានរដ្ឋបាលបុគ្គលិក |
| ៣- | លោកស្រី | ហាន សុលក្ខិណា | អនុប្រធាការិយាល័យនគ្រប់គ្រងមូលនិធិអន្តរជាតិ នៃនាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ |
| ៤- | លោក | អ៊ន់ បុត្រ | អនុប្រធានការិយាល័យស្រាវជ្រាវ និងវិភាគព័ត៌មាន នៃនាយកដ្ឋានព័ត៌មាន |



៤

| | | | |
|---|---|---|---|
| ៥- | លោកស្រី | ហាក់ បុប្ផារ័ត្ន | អនុប្រធានការិយាល័យឱកាសការងារស្ត្រី នៃនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៦- | លោកស្រី | អ៊ិន ចាន់ពុទ្ធីតា | អនុប្រធានការិយាល័យការពារផ្លូវច្បាប់ នៃមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ |
| ៧- | លោកស្រី | អេង ចាន់ណារី | ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តកណ្តាល |
| ៨- | លោកស្រី | មាន សុគន្ធារី | ប្រធានការិយាល័យផែនការ និងស្ថិតិ នៃមន្ទីរកិច្ចការនារីខេត្តកណ្តាល |
| ៩- | លោកស្រី | កើត សុខឿន | ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៃមន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង |
| ១០- | លោកស្រី | កែ កុម្ភៈគារី | ប្រធានការិយាល័យសមភាពយេនឌ័រ នៃមន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង |
| ១១- | លោកស្រី | ឡេង សុបូរ៉ាន់ | អនុប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ នៃមន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង |
| ១២- | លោកស្រី | ទិតធុន វិសុទ្ធី | អនុប្រធានការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃមន្ទីរកិច្ចការនារី ខេត្តពោធិ៍សាត់ |
| ១៣- | លោកស្រី | សយ សាវឌី | ប្រធានការិយាល័យបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តកោះកុង |
| ១៤- | លោក | ឡុង សុខុម | ប្រធានការិយាល័យស្ត្រីនិងសុខភាព-ស្ត្រីនិងការអប់រំ នៃមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៥- | លោកស្រី | គង់ ចំណិន | មន្ត្រី នៃមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៦- | លោកស្រី | ព្រាប ពុទ្ធារី | ប្រធានការិយាល័យស្ត្រី និងសុខភាព នៃមន្ទីរកិច្ចការនារីខេត្តព្រះសីហនុ |
| ១៧- | លោកស្រី | សឿង សំអាត | ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តក្រចេះ |
| ១៨- | លោកស្រី | គាត ឡាឌី | អនុប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់-ផែនការនិងស្ថិត នៃមន្ទីរកិច្ចការនារីខេត្តក្រចេះ |
| ១៩- | លោក | ប៉េង សុធីណា | ប្រធានការិយាល័យផ្សព្វផ្សាយតាមវិទ្យុ នៃនាយកដ្ឋានព័ត៌មាន |
| ២០- | លោកស្រី | យុត សុភក្តិ | ប្រធានការិយាល័យស្ត្រីនិងសុខភាព-ស្ត្រីនិងការអប់រំ នៃមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | អ៊ុក វណ្ណា | ជំនួយការរដ្ឋលេខាធិការ |
| ២- | លោកស្រី | សុខ ឡេង | ជំនួយការរដ្ឋលេខាធិការ |
| ៣- | លោកស្រី | សេន ហ្វាអ៊ីហ្សាស់ | ជំនួយការរដ្ឋលេខាធិការ |
| ៤- | លោកស្រី | ជ ស្រីមុំ | ជំនួយការរដ្ឋលេខាធិការ |
| ៥- | លោកស្រី | ផាន ពុទ្ធារតន៍ | ជំនួយការរដ្ឋលេខាធិការ |
| ៦- | លោកស្រី | ងួន ស្រីនិច | ជំនួយការរដ្ឋលេខាធិការ |
| ៧- | លោកស្រី | ស៊ឹប សុវិជ្ជា | មន្ត្រី នៃនាយកដ្ឋានផែនការនិងស្ថិតិ |
| ៨- | លោកស្រី | លី ហ៊ុយសួង | មន្ត្រី នៃនាយកដ្ឋានស្ត្រីនិងសុខភាព |

| | | | |
|---|---|---|---|
| ៩- | លោកស្រី | អេង សុខចាន់ | អនុប្រធានការិយាល័យស្ត្រីនិងសុខភាព-ស្ត្រីនិងការអប់រំ នៃមន្ទីរកិច្ចការនារីខេត្តកំពង់ចាម |
| ១០- | លោកស្រី | តេង គឹមហាន | មន្ត្រី នៃមន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ |
| ១១- | លោក | ហ៊ីម សំណាង | អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តព្រៃវែង |
| ១២- | លោកស្រី | ប៉ែន ដារីកា | ប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់ នៃមន្ទីរកិច្ចការនារីខេត្តស្វាយរៀង |
| ១៣- | លោកស្រី | ឃ្លោក សុផា | អនុប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់ នៃមន្ទីរកិច្ចការនារីខេត្តតាកែវ |
| ១៤- | លោកស្រី | នួន សូរិយា | ប្រធានការិយាល័យផែនការនិងស្ថិតិ នៃមន្ទីរកិច្ចការនារីខេត្តបាត់ដំបង |
| ១៥- | លោក | ម៉ៅ វេង | ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៦- | លោកស្រី | ញ៉ែន ស្មើ | ប្រធានការិយាល័យការពារផ្លូវច្បាប់ នៃមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ |
| ១៧- | លោក | ហែ ភារុណ | មន្ត្រី នៃមន្ទីរកិច្ចការនារីខេត្តប៉ៃលិន |
| ១៨- | លោកស្រី | គន្ធ រីនាថ | អនុប្រធានការិយាល័យហិរញ្ញវត្ថុនិងផ្គត់ផ្គង់-ផែនការនិងស្ថិតិ នៃមន្ទីរកិច្ចការនារីខេត្តព្រះវិហារ |
| ១៩- | លោក | ស៊ី ឌីន័ត្ត | មន្ត្រី នៃមន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង |
| ២០- | លោកស្រី | ព្រាំ សាលី | អនុប្រធានការិយាល័យស្ត្រីនិងសុខភាព-ស្ត្រីនិងការអប់រំ នៃមន្ទីរកិច្ចការនារីខេត្តមណ្ឌលគិរី |
| ២១- | លោក | ថន ម៉េងហុង | អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ |
| ២២- | លោក | ហេង ភាព៉ា | អនុប្រធានការិយាល័យព័ត៌មាន នៃមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៩ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- យោងតាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា



ម

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៧ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តមឧត្តមសេនីយ៍ឯក | **ឌី វិជ្ជា** | តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២- លោកជំទាវ | **សាយ សំអាត** | តំណាងធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ៣- ឯកឧត្តម | **ទេព តិយោរិទ្ធ** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤- លោកជំទាវ | **សុខ ឆវ័ន្ត** | តំណាងក្រសួងយុត្តិធម៌ | សមាជិកា |
| ៥- ឯកឧត្តម | **រិទ្ធ អារុណាទិត្យា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម | **ហោខ បូមករា** | ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | លេខាធិការ។ |

**មាត្រា២ .-**

អនុក្រឹត្យលេខ៨៩៥ អនក្រ.តត ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨០ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីនគរបាលជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបន្ថយឋានន្តរស័ក្តិចំនួន ១ថ្នាក់ ពីវរសេនីយ៍ឯក ពៅ សុផល អត្តលេខ ៧០៧៨៦ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ឱ្យមកនៅត្រឹមថ្នាក់ វរសេនីយ៍ទោ ។

៩

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ក្រសួងមហាផ្ទៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្តិ លោក មិត្ត សារុន អត្តលេខ០៦៤៥ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ២ មកជា ឋានន្តរស័ក្តិវរអគ្គានុរក្សថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៦

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨១២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ ..**

ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ៦រូប៖

១- វរសេនីយ៍ទោ **សោម ហោ** អត្តលេខ ៣១៦៧១
២- វរសេនីយ៍ទោ **កេត សុផានី** អត្តលេខ ៣៣៨៧១
៣- វរសេនីយ៍ទោ **ម៉ី ប៊ាន** អត្តលេខ ៥៧៧៦៦
៤- វរសេនីយ៍ទោ **តាំង ឈាងខេង** អត្តលេខ ៦០២៥៨
៥- វរសេនីយ៍ទោ **វង្ស ច័ន្ទរស្មី** អត្តលេខ ៧១៣៦៧
៦- វរសេនីយ៍ទោ **លី វណ្ណា** អត្តលេខ ៨៧៣៥០។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើតខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៣...អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោកស្រី ធន រតនា សមាជិកា នៃគណៈកម្មាធិការជាតិរៀបចំវចនានុក្រមខ្មែរ ដែលមានស្នាដៃល្អក្នុងការពិនិត្យនិងរៀបចំវចនានុក្រមខ្មែរឆ្នាំ២០២២កន្លងមក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ប្រាក់ការងារ** ជូនលោកស្រី អ៊ុយ រ៉ាវីផល សមាជិកា នៃគណៈកម្មាធិការជាតិរៀបចំវចនានុក្រមខ្មែរ ដែលមានស្នាដៃល្អក្នុងការពិនិត្យនិងរៀបចំវចនានុក្រមខ្មែរឆ្នាំ២០២២កន្លងមក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តព្រះសីហនុ ចំនួន ១៤៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ជា ពិសិដ្ឋនរៈ | អភិបាលរង នៃគណៈអភិបាលក្រុងកោះរ៉ុង |
| ២- | លោក | ខឹម សុផល | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ |
| ៣- | លោក | ហេង សុខគុន | ប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ៤- | លោក | រ័ត្ន វាសនា | អនុប្រធានការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុងកំពង់សោម |
| ៥- | លោកស្រី | សួន សុវិធានៈ | នាយិកាសាលាបឋមសិក្សាធីស៊ីកំពង់សីលា ស្រុកកំពង់សីលា |

៦- លោក អ៊ុង ចន្ធា នាយកសាលាបឋមសិក្សាព្រៃប្រសិទ្ធិ ស្រុកកំពង់សីលា
៧- លោក វណ្ណ ចន្ថា នាយកសាលាបឋមសិក្សាសម្ដេចតា ស្រុកកំពង់សីលា
៨- លោក ប៉ុល បញ្ញា នាយកសាលាបិតត្រាំងមិត្តភាពព្រះសីហនុជាំងស៊ូ ក្រុងកំពង់សោម
៩- លោកស្រី ក្រូច ផល្លា នាយិកាសាលាបឋមសិក្សាបឹងតាព្រហ្ម ក្រុងកំពង់សោម
១០- លោកស្រី ម៉ូ ស្រីអូន លេខាធិការសាលាបឋមសិក្សាស្ទឹងប្រាល ស្រុកកំពង់សីលា
១១- លោក ប៊ុន បូរិន គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន កំពង់សីលា ស្រុកកំពង់សីលា
១២- លោក ម៉េង សំបូរ មន្ត្រី នៃរដ្ឋបាលស្រុកកំពង់សីលា
១៣- លោក ខាន់ ចាន់ថេរ មន្ត្រី នៃរដ្ឋបាលក្រុងព្រះសីហនុ
១៤- លោកស្រី ជៀក ស៊ីណា ស្មៀនសង្កាត់លេខ៣ ក្រុងព្រះសីហនុ
១៥- លោក ហួត ម៉ូរ៉ា អនុប្រធានការិយាល័យ រដ្ឋបាលស្រុកព្រៃនប់
១៦- លោក សំរិទ្ធ សុភា អនុប្រធានការិយាល័យ រដ្ឋបាលស្រុកព្រៃនប់
១៧- លោក ខៀវ ចាន់ដារ៉ា មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់
១៨- លោក សុខ ពៅ នាយកសាលាបឋមសិក្សាសំរុង ស្រុកព្រៃនប់
១៩- លោក ស អ៊ុយ គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន តានៃ ស្រុកព្រៃនប់
២០- លោកស្រី ឯម វណ្ណៈ គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន វាលរេញ ស្រុកព្រៃនប់
២១- លោក ខួន សុផល គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ព្រៃនប់ ស្រុកព្រៃនប់។

ខ-មេដាយ **ប្រាក់ការងារ**

១- លោក ពេជ្រ ខៅដាង នាយករងរដ្ឋបាលខេត្តព្រះសីហនុ
២- លោក ជា បាឈុន នាយកទីចាត់ការ រដ្ឋបាលខេត្តព្រះសីហនុ
៣- លោក ម៉ែ វ៉ាន់ណារិន នាយករងទីចាត់ការ រដ្ឋបាលខេត្តព្រះសីហនុ
៤- លោក ទៀង វណ្ណារិទ្ធ អភិបាលរង នៃគណៈអភិបាលក្រុងព្រះសីហនុ
៥- លោក អែម រ័ត្នម៉ានិល អភិបាលរង នៃគណៈអភិបាលក្រុងកោះរ៉ុង
៦- លោក លី ចិត្តនិយម ប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
៧- លោកស្រី យន់ សុថារ័ត្ន ប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
៨- លោក ង៉ែត កំពូល ប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
៩- លោក ឡុង ប៊ុនសៀង អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
១០- លោក ហួន គុណា អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
១១- លោក ហួយ វ៉ាន់ថន អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
១២- លោក ហាក់ ចាន់ណា អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
១៣- លោកស្រី ម៉ក់ ចាន់ណា អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ
១៤- លោក លឹម គុណអាន មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ
១៥- លោក ចិន ផានិត នាយករងរដ្ឋបាលស្រុកកំពង់សីលា

| | | | |
|---|---|---|---|
| ១៦- | លោក | ពិសាល មិថុនា | នាយករងរដ្ឋបាលក្រុងកំពង់សោម |
| ១៧- | លោកស្រី | អៀ យាងឡេង | ប្រធានការិយាល័យ រដ្ឋបាលក្រុងកោះរ៉ុង |
| ១៨- | លោក | អៀង យ៉ា | ប្រធានការិយាល័យ រដ្ឋបាលក្រុងកោះរ៉ុង |
| ១៩- | លោក | ស៊ុំ យន | ប្រធានការិយាល័យ រដ្ឋបាលក្រុងព្រះសីហនុ |
| ២០- | លោក | ហេង លីទ្រី | ប្រធានការិយាល័យ រដ្ឋបាលក្រុងព្រះសីហនុ |
| ២១- | លោកស្រី | ម៉ៅ វណ្ណនី | ប្រធានការិយាល័យ រដ្ឋបាលស្រុកព្រៃនប់ |
| ២២- | លោក | ជី គីមឈន់ | ប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ២៣- | លោកស្រី | ឌី ស៊ីវហ៊ួន | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ២៤- | លោក | សោម ហួត | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកព្រៃនប់ |
| ២៥- | លោកស្រី | គង់ ស៊ីនួន | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ២៦- | លោក | ទូច នន | អនុប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ២៧- | លោក | ស្មាន សាលេស | អនុប្រធានការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុងព្រះសីហនុ |
| ២៨- | លោក | ថាំ វ៉ាណា | មន្ត្រី នៃរដ្ឋបាលក្រុងព្រះសីហនុ |
| ២៩- | លោកស្រី | សន ស្រីនួ | មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ |
| ៣០- | លោក | អាន ណារី | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកកំពង់សីលា |
| ៣១- | លោក | ទឹម ជ្រុន | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ៣២- | លោកស្រី | ទុន លីគាន | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ៣៣- | លោក | ឡុង រដ្ឋា | មន្ត្រី នៃរដ្ឋបាលក្រុងកំពង់សោម |
| ៣៤- | លោក | សើ យ៉ើ | ស្មៀនសង្កាត់អូរជ្រៅ ក្រុងកំពង់សោម |
| ៣៥- | លោក | ស៊ន លីសារ | នាយករងសាលាបឋមសិក្សាសម្តេចតា ស្រុកកំពង់សីលា |
| ៣៦- | លោក | ចាន់ លិកា | គ្រូបង្រៀនសាលាបឋមសិក្សាស្ទឹងប្រាល ស្រុកកំពង់សីលា |
| ៣៧- | លោកស្រី | ខាត់ ស្រីជៀប | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេចតា ស្រុកកំពង់សីលា |
| ៣៨- | លោកស្រី | ទ្រី ស្រីណេត | គ្រូបង្រៀនសាលាបឋមសិក្សាគីរីវន្ត ស្រុកកំពង់សីលា |
| ៣៩- | លោកស្រី | ប្រុស ស្រីវាង | គ្រូបង្រៀនសាលាបឋមសិក្សាគីរីវន្ត ស្រុកកំពង់សីលា |
| ៤០- | លោក | ប្រុស សុភាព | គ្រូបង្រៀនសាលាបឋមសិក្សាគីរីវន្ត ស្រុកកំពង់សីលា |
| ៤១- | លោកស្រី | សុខ សារិន | គ្រូបង្រៀនសាលាបឋមសិក្សាទួលទទឹង ស្រុកព្រៃនប់ |
| ៤២- | លោក | សាញ់ សុជាតិ | គ្រូបង្រៀនសាលាបឋមសិក្សាសំរុង ស្រុកព្រៃនប់ |
| ៤៣- | លោក | យូ សំណាង | គ្រូបង្រៀនសាលាបឋមសិក្សាទួលទទឹង ស្រុកព្រៃនប់ |
| ៤៤- | លោកស្រី | កេង ស្រីនង | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន វាលរេញ ស្រុកព្រៃនប់ |
| ៤៥- | លោក | ប៊ិត សុខហេង | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន វាលរេញ ស្រុកព្រៃនប់ |
| ៤៦- | លោក | ហេង គីមអេង | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន បត់សិរមាន់ ស្រុកព្រៃនប់ |
| ៤៧- | លោក | ស៊ីវ ភាព | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន អណ្ដូងថ្ម ស្រុកព្រៃនប់។ |

គ-មេងាយ **សំរឹទ្ធភាពរខារ**

| | | | |
|---|---|---|---|
| ១- | លោក | ហ៊ួត ហ៊ុយ | នាយករងរដ្ឋបាលខេត្តព្រះសីហនុ |
| ២- | លោក | ហុង សុខហួរ | នាយកទីចាត់ការ រដ្ឋបាលខេត្តព្រះសីហនុ |
| ៣- | លោកស្រី | ហួត ឆាយណា | ប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ |
| ៤- | លោកស្រី | សាន សូម៉ាឡៃ | ប្រធានអង្គភាពលទ្ធកម្ម រដ្ឋបាលក្រុងព្រះសីហនុ |
| ៥- | លោក | យូ ចាន់ណា | ប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ៦- | លោក | ជិន សាម៉ន | ប្រធានការិយាល័យ រដ្ឋបាលក្រុងកំពង់សោម |
| ៧- | លោកស្រី | ប៉ែន ឌីណា | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ |
| ៨- | លោក | ផល សុភា | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ |
| ៩- | លោក | សុខ សាម៉ន | មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ |
| ១០- | លោក | គង់ ប៊ុនទ្រី | អនុប្រធានការិយាល័យ រដ្ឋបាលខេត្តព្រះសីហនុ |
| ១១- | លោក | ម៉ី ម៉េាង | មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ |
| ១២- | លោក | លី ឆាយ | មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ |
| ១៣- | លោក | ញឹម សុផាត | មន្ត្រី នៃរដ្ឋបាលខេត្តព្រះសីហនុ |
| ១៤- | លោក | ផន សាវន | អនុប្រធានការិយាល័យ រដ្ឋបាលស្រុកព្រៃនប់ |
| ១៥- | លោក | អ៊ឹង ចាន់ជា | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ១៦- | លោក | ម៉ន ញឹម | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ១៧- | លោក | ពេជ វាសនា | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ១៨- | លោកស្រី | នាង វិច្ឆិកា | មន្ត្រី នៃរដ្ឋបាលស្រុកព្រៃនប់ |
| ១៩- | លោក | ទី ជីវ័ន្ត | មន្ត្រី នៃរដ្ឋបាលក្រុងកំពង់សោម |
| ២០- | លោក | វ៉េង បូរ៉េ | មន្ត្រី នៃរដ្ឋបាលក្រុងកំពង់សោម |
| ២១- | លោក | សឿង សុធារិន | មន្ត្រី នៃរដ្ឋបាលក្រុងកំពង់សោម |
| ២២- | លោក | ច័ន្ទ សុភ័ក្ត្រ | ស្មៀនសង្កាត់រាម ក្រុងកំពង់សោម |
| ២៣- | លោក | ជា សុវណ្ណ | នាយកសាលាបឋមសិក្សា ហ៊ុន សែន ភ្ជោង ស្រុកកំពង់សីលា |
| ២៤- | លោក | ទឹម ហឿន | គ្រូបង្រៀនសាលាបឋមសិក្សាស្នាច់ដែង ក្រុងកំពង់សោម |
| ២៥- | លោក | ហែម គន្ធា | គ្រូបង្រៀនសាលាបឋមសិក្សាស្នាច់ដែង ក្រុងកំពង់សោម |
| ២៦- | លោកស្រី | ស្រេង ធូក | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ភ្ជោង ស្រុកកំពង់សីលា |
| ២៧- | លោកស្រី | សាំង សុថារី | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន កំពង់សីលា ស្រុកកំពង់សីលា |
| ២៨- | លោកស្រី | អេង នារឌី | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន កំពង់សីលា ស្រុកកំពង់សីលា |
| ២៩- | លោកស្រី | ឡុង សុខេង | លេខាធិការសាលាបឋមសិក្សាស្ទឹងសំរោង ស្រុកកំពង់សីលា |
| ៣០- | លោកស្រី | ឡាយ ស៊ីណា | គ្រូបង្រៀនសាលាបឋមសិក្សាស្ទឹងសំរោង ស្រុកកំពង់សីលា |
| ៣១- | លោកស្រី | យ៉ាង លីឌី | គ្រូបង្រៀនសាលាបឋមសិក្សាគីរីវ័ន្ត ស្រុកកំពង់សីលា |

| | | | |
|---|---|---|---|
| ៣២- | លោក | បាន បញ្ញា | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ស្ទឹងឆាយ ស្រុកកំពង់សីលា |
| ៣៣- | លោកស្រី | មាស ចាន់វ័ឌ្ឍនា | បណ្ណារក្សសាលាបឋមសិក្សាសម្តេចតា ស្រុកកំពង់សីលា |
| ៣៤- | លោកស្រី | បែន និតារ | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេចតា ស្រុកកំពង់សីលា |
| ៣៥- | លោកស្រី | ស៊ុន សុជារី | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេចតា ស្រុកកំពង់សីលា |
| ៣៦- | លោកស្រី | សម្បូរ ឡៃគីម | គ្រូបង្រៀនសាលាបឋមសិក្សាជីស៊ីកំពង់សីលា ស្រុកកំពង់សីលា |
| ៣៧- | លោកស្រី | ជ័យ សោភ័ណ្ឌ | គ្រូបង្រៀនសាលាបឋមសិក្សាភូមិថ្មី ស្រុកកំពង់សីលា |
| ៣៨- | លោក | យួង យ៉ុង | មន្ត្រី នៃរដ្ឋបាលស្រុកកំពង់សីលា |
| ៣៩- | លោក | សុខ ព្រឹកព្រាង | ស្មៀនសង្កាត់កោះរ៉ុងសន្លឹម ក្រុងកោះរ៉ុង |
| ៤០- | លោក | កែវ មុនាត | គ្រូបង្រៀនសាលាបឋមសិក្សាកោះរ៉ុងសន្លឹម ក្រុងកោះរ៉ុង |
| ៤១- | លោកស្រី | វឿន វល័ក្ខ | គ្រូបង្រៀនសាលាបឋមសិក្សាកោះរ៉ុងសន្លឹម ក្រុងកោះរ៉ុង |
| ៤២- | លោកស្រី | គ្រី ចាន់និម្មល | គ្រូបង្រៀនសាលាបឋមសិក្សាភូមិសុខសាន្ត ក្រុងកោះរ៉ុង |
| ៤៣- | លោក | រ៉ា ឆៃល័ក្ខ | គ្រូបង្រៀនសាលាបឋមសិក្សាភូមិសុខសាន្ត ក្រុងកោះរ៉ុង |
| ៤៤- | លោកស្រី | ដាញ់ ឌី | គ្រូបង្រៀនសាលាបឋមសិក្សាកោះតូច ក្រុងកោះរ៉ុង |
| ៤៥- | លោកស្រី | អ៊ុក ពៅពិសី | គ្រូបង្រៀនសាលាបឋមសិក្សាកោះតូច ក្រុងកោះរ៉ុង |
| ៤៦- | លោក | អ៊ិន ធឿន | គ្រូបង្រៀនសាលាបឋមសិក្សាដើមថ្កូវ ក្រុងកោះរ៉ុង |
| ៤៧- | លោក | មោក គូ | គ្រូបង្រៀនសាលាបឋមសិក្សាដើមថ្កូវ ក្រុងកោះរ៉ុង |
| ៤៨- | លោកស្រី | សិទ្ធ សាវ៉ាន | គ្រូបង្រៀនសាលាបឋមសិក្សាដើមថ្កូវ ក្រុងកោះរ៉ុង |
| ៤៩- | លោក | ជា ចាន់ណារី | គ្រូបង្រៀនសាលាបឋមសិក្សាព្រែកស្វាយ ក្រុងកោះរ៉ុង |
| ៥០- | លោកស្រី | ហុក យីដា | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥១- | លោក | ឈុន សុន | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥២- | លោក | លាស បូរ៉ា | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥៣- | លោក | មួន យុនឡា | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥៤- | លោកស្រី | ណុប កល្យាណ | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥៥- | លោក | ម៉ែល សាម៉ុន | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥៦- | លោកស្រី | សេង ម៉ាលីកា | គ្រូបង្រៀនសាលាបឋមសិក្សាសម្តេច ជា ស៊ីម ក្រុងព្រះសីហនុ |
| ៥៧- | លោកស្រី | ឆេង ច័ន្ទលក្ខិណា | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៥៨- | លោកស្រី | អ៊ឹម ទិត្យានុភាព | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៥៩- | លោកស្រី | សាន សុណ្ណារី | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៦០- | លោក | ភិន ផេង | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៦១- | លោកស្រី | យិន ចំណាន | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៦២- | លោកស្រី | គិន កុមារី | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |
| ៦៣- | លោក | ជា ម៉េត | គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ |

៦៤- លោកស្រី ព្រំ ទិត្យស៊ុនណារី គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ
៦៥- លោកស្រី វ័ន្ត ចន្នី គ្រូបង្រៀនសាលាបឋមសិក្សាផ្សារលើ ក្រុងព្រះសីហនុ
៦៦- លោកស្រី ត្លួយ ធីតា គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន តានៃ ស្រុកព្រៃនប់
៦៧- លោកស្រី អ៊ុយ ចាន់ណា គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន តានៃ ស្រុកព្រៃនប់
៦៨- លោកស្រី ឡុង ញ៉ាញ់ គ្រូបង្រៀនសាលាបឋមសិក្សាសាមគ្គី ស្រុកព្រៃនប់
៦៩- លោកស្រី ស៊ុន លក្ខិណា គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន តានៃ ស្រុកព្រៃនប់
៧០- លោកស្រី រី ចាន់ដេត គ្រូបង្រៀនសាលាបឋមសិក្សាសាមគ្គី ស្រុកព្រៃនប់
៧១- លោក អ៊ិច វណ្ណនឿន គ្រូបង្រៀនសាលាបឋមសិក្សាណារុគីបឹងរាំង ស្រុកព្រៃនប់
៧២- លោក អ៊ិន ស៊ីណាត គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន អណ្តូងថ្ម ស្រុកព្រៃនប់
៧៣- លោកស្រី លឹម ណារី គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ព្រៃនប់ ស្រុកព្រៃនប់
៧៤- លោកស្រី ប៉ាង ស៊ីណា គ្រូបង្រៀនសាលាបឋមសិក្សាសំរុង ស្រុកព្រៃនប់
៧៥- លោកស្រី មឿន ចាន់រស្មី គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន វាលរេញ ស្រុកព្រៃនប់
៧៦- លោកស្រី ណុប សាវឌី គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ព្រៃនប់ ស្រុកព្រៃនប់
៧៧- លោក សោម ខឿន គ្រូបង្រៀនសាលាបឋមសិក្សាសំរុង ស្រុកព្រៃនប់
៧៨- លោក ឡឺ រ៉ាត គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន អណ្តូងថ្ម ស្រុកព្រៃនប់
៧៩- លោក ថន ផុន គ្រូបង្រៀនសាលាបឋមសិក្សាណារុគីបឹងរាំង ស្រុកព្រៃនប់។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨៦ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្មើនាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



៩

## សម្រេច

**មាត្រា ១ .–**

ត្រូវបានតែងតាំងលោក **ឆាម ហោច** អត្តលេខ ១៧៣១០០០១២០ ឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៣ នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម ជាប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ នៃក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៧៤ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



៩៥

**សម្រេច**

**មាត្រា ១.-**

ត្រូវបានតែងតាំងលោកស្រី **ជាតិ រតនៈវតី** អត្តលេខ ២៩៨៤១២០០១៦៨ ឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម ជាប្រធាននាយកដ្ឋានរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **ហាន វីរៃ** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៨...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូប៖

១- វរសេនីយ៍ទោ **កឿង រតនា** អត្តលេខ ១១៤៧២

២- វរសេនីយ៍ទោ **សេក ឡុងឌី** អត្តលេខ ៥៥០៣៤។

**មាត្រា២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើតខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៩ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូបៈ

១- វរសេនីយ៍ទោ **ស៊ន់ តារាឧុញ្ញ** អត្តលេខ ៦២៦៩២

២- វរសេនីយ៍ទោ **ស៊ុំ ប៊ុនថេត** អត្តលេខ ៦៣១៥២។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើតខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩០ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសុវត្ថារា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ៥រូប ដូចមានរាយនាមខាងក្រោម៖

១- អនុសេនីយ៍ទោ មេង សៅហេង

២- ព្រឹន្ទបាលទោ មឿន ពិទូ

៣- អនុសេនីយ៍ទោ រិទ្ធី ស៊ូរ៉ាយុទ្ធ

៤- អនុសេនីយ៍ទោ អឿន សំអៀង

៥- អនុសេនីយ៍ត្រី ស្រេង សៀកលីម។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើតខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩១ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន ២២អង្គ/រូប ដូចមានរាយព្រះនាម និងនាមខាងក្រោមៈ

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- ព្រះមុនីសរណធម្ម សន ច័ន្ទឌី
២- វរសេនីយ៍ទោ ឆេង ធន្ធៃ
៣- វរសេនីយ៍ទោ រឿន គីមស្រៀង
៤- លោក មឿន ចន្ទ្រា
៥- លោក ផង់ ពន្លៃ

៦- អនុសេនីយ៍ឯក ឡាង សុជានី
៧- អនុសេនីយ៍ទោ កែវ សុវណ្ណវិចៃ
៨- អនុសេនីយ៍ទោ អ៊ូន ឃុនសេនី
៩- វរសេនីយ៍ត្រី ធូ ច័ន្ទកិរុណ
១០- វរសេនីយ៍ទោ ជិន រតនៈ
១១- អនុសេនីយ៍ឯក ម៉ាត់ រ៉ាវី
១២- ទន្តបណ្ឌិត លី ធីរៈ។

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- ភិក្ខុ ឌុម ឃាមុនី
២- លោក ប៊ុន ភក្តី
៣- វរសេនីយ៍ត្រី រ៉ាន់ ជីវ័ន្ត
៤- វរសេនីយ៍ត្រី សោម ជីសែន
៥- ព្រឹទ្ធបាលទោ អ៊ឹម មុន្នីរតនា
៦- អនុសេនីយ៍ឯក នាង ច័ន្ទសុវណ្ណ
៧- អនុសេនីយ៍ឯក យ៉េ ឆៃយ៉ា។

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោកស្រី ភិន ណាលីន
២- វរសេនីយ៍ឯក ម៉ាន់ ដាវីត
៣- លោក ផន វុត្ថា។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩២ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១០៥រូប ដូចមានរាយនាមខាងក្រោម៖

ក- មេដាយ **មាសស្ថាបនាជាតិ**

១- អនុសេនីយ៍ទោ ប៉ូ ការុណ
២- អនុសេនីយ៍ទោ នៅ គុណា
៣- អនុសេនីយ៍ទោ រិន សុភារស់

| | |
|---|---|
| ៤- អនុសេនីយ៍ទោ | សំ វ៉ាន់ហោ |
| ៥- អនុសេនីយ៍ទោ | សៅ ចិន្តា |
| ៦- អនុសេនីយ៍ទោ | អ៊ឹង សុខពៅ |
| ៧- អនុសេនីយ៍ទោ | ហេង ដាវ៉ារុធ |
| ៨- អនុសេនីយ៍ទោ | អុន អូណាម៉ាណាន់ |
| ៩- អនុសេនីយ៍ទោ | ចាន់ បូរ៉េត |
| ១០- អនុសេនីយ៍ត្រី | ឡូត យុនរី |
| ១១- អនុសេនីយ៍ឯក | ថាន់ វ៉ារ៉ុង |
| ១២- លោក | អ៊ុន វ៉ាន់ខៃ |
| ១៣- អនុសេនីយ៍ត្រី | ទិត ចំណាប់ |
| ១៤- សាស្ត្រាចារ្យជំនួយ | លីម អាស៊ីគីន |
| ១៥- លោក | អ៊ុន សីហា |
| ១៦- លោក | ប្រាក់ សង្ហា |
| ១៧- អនុសេនីយ៍ត្រី | សោម ស្រីសរ |
| ១៨- វរសេនីយ៍ត្រី | សោម ហាវ៉ៃ |
| ១៩- អនុសេនីយ៍ទោ | យឹន សុខម៉េង |
| ២០- លោក | ទេស លីជីង |
| ២១- ព្រឹន្ទបាលទោ | ងឿន គឹមឈិញ |
| ២២- អនុសេនីយ៍ត្រី | ជា ពុទ្ធី |
| ២៣- អនុសេនីយ៍ទោ | កាំង ហេឡាយ |
| ២៤- វរសេនីយ៍ត្រី | អ៊ុំ វណ្ណៈ |
| ២៥- អនុសេនីយ៍ឯក | ឈាក់ សារ៉ែន |
| ២៦- អ្នកអង្គម្ចាស់បណ្ឌិត | ស៊ីសុវត្ថិ ឫទ្ធីរ៉ាវង្ស |
| ២៧- អនុសេនីយ៍ត្រី | ពេជ្រ ស្រីមី |
| ២៨- ព្រឹន្ទបាលទោ | ពេជ្រ ភក្តី |
| ២៩- អនុសេនីយ៍ត្រី | វណ្ណា ម៉ូហាំម៉ាត់រិទ្ធដាវ៉ាន |
| ៣០- អនុរក្សថ្នាក់លេខ៣ | យុង យុត្តានុត |
| ៣១- អនុរក្សថ្នាក់លេខ១ | ពៅ សុភ័ស |
| ៣២- សាស្ត្រាចារ្យ | សឿង រតនា |
| ៣៣- លោក | ប៊ុន សេរីរិទ្ធ |
| ៣៤- លោក | សែស ស៊ីថា |
| ៣៥- លោក | ហាវ សំបូរ |
| ៣៦- លោក | យ៉ាត យ៉េត |
| ៣៧- វរសេនីយ៍ទោ | ញ៉ែម រស្មី |

| | |
|---|---|
| ៣៨- វរសេនីយ៍ត្រី | នាង ឧត្តម |
| ៣៩- អនុសេនីយ៍ត្រី | ហួត គឹមហុង |
| ៤០- ព្រឹន្ទបាលទោ | ស៊ន់ ណារិន |
| ៤១- ព្រឹន្ទបាលទោ | ធន់ ថារិទ្ធិ |
| ៤២- ព្រឹន្ទបាលទោ | ហៀង ប៊ុនហេង |
| ៤៣- លោកជំទាវ | ជួន លក្ខិណា |
| ៤៤- លោក | សាន ច័ន្ទអង្គារ៉ា |
| ៤៥- អនុសេនីយ៍ត្រី | ទ្រី តាំងផេង |
| ៤៦- អនុសេនីយ៍ត្រី | ស៊ិន សុនីន |
| ៤៧- លោក | គុន សុខភារុណ |
| ៤៨- លោក | ញឹម សោភ័ណ្ឌ |
| ៤៩- លោក | និត វិចិត្រ |
| ៥០- វរសេនីយ៍ត្រី | សុក លីនដា |
| ៥១- លោក | សំ ប្រាកដ |
| ៥២- លោក | លីវ លឿ |
| ៥៣- លោក | អៀម សំអុល |
| ៥៤- វរសេនីយ៍ទោ | ង៉ែត រតនា |
| ៥៥- វរសេនីយ៍ទោ | មាស បញ្ញា |
| ៥៦- វរសេនីយ៍ត្រី | គឹម សារ៉ាន់ |
| ៥៧- វរសេនីយ៍ត្រី | គាន ខាន់វ៉ាន់ដា |
| ៥៨- អនុសេនីយ៍ឯក | គង់ ម៉ារ៉ាដារ |
| ៥៩- លោកស្រី | អួន ហ្វីយ៉ែត |
| ៦០- ព្រឹន្ទបាលឯក | វ៉ាត វាសនា |
| ៦១- បណ្ឌិត | អ៊ឹម សិរីវឌ្ឍ |
| ៦២- អនុសេនីយ៍ត្រី | ជួប វាសនា |
| ៦៣- អនុសេនីយ៍ឯក | ហេង រដ្ឋធី |
| ៦៤- អនុសេនីយ៍ទោ | តិច ស្មើ |
| ៦៥- អនុសេនីយ៍ទោ | វ៉ាន់ សុកន |
| ៦៦- អនុសេនីយ៍ត្រី | ច័ន្ទធឿន ណារិទ្ធ |
| ៦៧- ឯកឧត្តមបណ្ឌិត | ឡុត ឡើយ |
| ៦៨- ឧកញ៉ា | កួយ ឡេសាន |
| ៦៩- Mr. | YAP TING CHIAT |
| ៧០- លោក | ម៉ើ ផល្លា |
| ៧១- លោក | ឆេង លីមស្រេង |

៧២- លោក កែវ ច័ន្ទណារុន
៧៣- លោកស្រី កុយ ធារី
៧៤- លោក សេង វិសិទ្ធ
៧៥- លោក ហួត លីហួ
៧៦- វរសេនីយ៍ទោ រឿន សាយកន
៧៧- លោក ធឹង ភារុន
៧៨- ឧបាសិកា នា ឥន្ទស៊ីនីន
៧៩- អនុសេនីយ៍ទោ ឡុង សុវណ្ណរតនា
៨០- លោក ម៉ម មករា
៨១- លោកស្រី យុន សំអេង
៨២- លោកស្រី យ៉ែម ពេជ្យរចនា
៨៣- លោកស្រី សួស មុិច
៨៤- លោកស្រី ហែម វត្តនា
៨៥- លោកស្រី យុន សុខេង
៨៦- លោក សុង ឆេងហាប់
៨៧- អនុសេនីយ៍ឯក អ៊ឹម គីមហុិយ
៨៨- លោក កែវ រដ្ឋា
៨៩- លោកស្រី ប៉ិច ស្រីនុច
៩០- លោក ជុន ម៉េងជាវ
៩១- លោក គុប សុច័ន្ទតារារតន
៩២- អនុសេនីយ៍ឯក ហាង់ វណ្ណារិទ្ធ
៩៣- លោក គីម តឹក
៩៤- អនុសេនីយ៍ត្រី រ៉ាស៊ី បរិមា
៩៥- អនុសេនីយ៍ឯក នូ ភារម្យ
៩៦- អនុសេនីយ៍ត្រី ឌី ណាវ
៩៧- លោក ស្វាយ ពិសិដ្ឋ។

ខ- មេដាយ **ប្រាក់ស្ថាបនាជាតិ**

១- លោក អាត រ៉ាតីប
២- លោកស្រី លាង សុខឡូត
៣- លោក ប៊ុន ប៉ែន
៤- លោកស្រី កែវ ម៉ារីណា
៥- ឧបាសិកា ម៉ុង សុខឃាន់
៦- អាចារ្យ ព្រុំ ប៊ុនធឿន
៧- លោក អេង ចន្ទី

៨-លោក ហ៊ាង សុផល។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើតខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០ សសរ

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការចាត់តាំងរដ្ឋលេខាធិការប្រចាំការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០១៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្ដីទី
- បានឃើញសេចក្ដីសម្រេចលេខ៨៩ សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

## សម្រេច

**ប្រការ១.-**

ចាត់តាំងឯកឧត្តម **គីម សុភ័ណ** ជារដ្ឋលេខាធិការប្រចាំការ ជំនួសឯកឧត្តម **ជា អូន** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ នឹងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១ កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៨១ សហវ.ឃ.ក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះ កំណត់អំពីនីតិវិធីក្នុងការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចសន្យា ដែលអនុវត្តដោយអ្នកផ្គត់ផ្គង់/អ្នកទទួលការ ជាមួយស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីធានាឱ្យការអនុវត្តកិច្ចសន្យា ប្រព្រឹត្តដោយរលូន ត្រឹមត្រូវ និងស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពលើគ្រប់កិច្ចសន្យាទំនិញ សំណង់ និងសេវាកម្មដែលប្រើប្រាស់ថវិកាជាតិ រវាង ស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកផ្គត់ផ្គង់/អ្នកទទួលការ លើកលែងតែកិច្ចសន្យាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងកិច្ចសន្យាដែលបានអនុវត្តតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

## ជំពូកទី២
## ការទទួលខុសត្រូវលើការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចសន្យា
## ផ្នែកទី១
## ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

**ប្រការ៣ ._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ ដែលមានអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាសេនាធិការ មានភារកិច្ចលើការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចសន្យាទំនិញ សំណង់ និងសេវាកម្ម ដែលបានទទួលការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤ ._**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានភារកិច្ចជាអាទិ៍ដូចខាងក្រោម៖

- ផ្តល់ការណែនាំ ជំរុញ និងតម្រង់ទិសដល់គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីអនុវត្តកិច្ចសន្យា ឱ្យបានរលូន ត្រឹមត្រូវ និងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា
- ផ្តល់ការសម្របសម្រួលអំពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាដល់គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម
- ផ្តល់ការសម្របសម្រួលជាមួយស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងករណីមានការស្នើសុំអន្តរាគមន៍ពីអ្នកផ្គត់ផ្គង់/អ្នកទទួលការ ពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា
- ចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកិច្ចសន្យា នៅស្ថាប័នអនុវត្តលទ្ធកម្ម
- លើកឡើងនូវដំណោះស្រាយនិងវិធានការនានាពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងការអនុវត្តកិច្ចសន្យា ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យសម្រេច។

## ផ្នែកទី២
## ស្ថាប័នអនុវត្តលទ្ធកម្ម

**ប្រការ៥ ._**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួលខុសត្រូវគ្រប់គ្រងផ្ទាល់លើការអនុវត្តកិច្ចសន្យា ដើម្បីធានាការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានរលូន ត្រឹមត្រូវ និងស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

**ប្រការ៦ ._**

គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម នៃស្ថាប័នអនុវត្តលទ្ធកម្ម មានភារកិច្ចជាអាទិ៍ដូចខាងក្រោម៖

- ផ្តល់ការណែនាំ ជំរុញ និងតម្រង់ទិសដល់អ្នកផ្គត់ផ្គង់/អ្នកទទួលការ ដើម្បីអនុវត្តកិច្ចសន្យាឱ្យបានរលូន ត្រឹមត្រូវ និងស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចសន្យា ដើម្បីធានាថាអ្នកផ្គត់ផ្គង់/អ្នកទទួលការ អនុវត្តឱ្យបានម៉ឺងម៉ាត់តាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងគុណភាពនៃការងារជាប្រចាំ រួមទាំងផ្ទៀងផ្ទាត់អនុលោមភាពតាមគំរូកាតាឡុក បទដ្ឋានលក្ខណៈបច្ចេកទេស គំនូសប្លង់ និងប្រតិទិនការងារ
- លើកសំណើសុំការកែប្រែ ពន្យារពេលអនុវត្ត ឬលុបកិច្ចសន្យា (ចំពោះកិច្ចសន្យាដែលបានពិនិត្យសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឱ្យបានទាន់ពេល ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច
- សម្របសម្រួលការប្រគល់ទទួល និងត្រួតពិនិត្យគុណភាពនិងបរិមាណទំនិញ/សំណង់/សេវាកម្មដូចកំណត់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា
- ពិនិត្យនិងដោះស្រាយវិវាទជាមួយអ្នកផ្គត់ផ្គង់/អ្នកទទួលការ ពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា
- ចេញវិញ្ញាបនបត្រ/លិខិតបញ្ជាក់បញ្ចប់ការងារ១០០%, វិញ្ញាបនបត្រ/លិខិតបញ្ជាក់លើការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ
- ផ្តល់ដំណោះស្រាយនិងចាត់វិធានការនានាពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងការអនុវត្តកិច្ចសន្យា ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ពិនិត្យសម្រេច
- សហការជាមួយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យា
- បញ្ជូនឯកសារស្នើសុំទូទាត់របស់អ្នកផ្គត់ផ្គង់/អ្នកទទួលការ ទៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុឱ្យបានទាន់ពេល។

## ផ្នែកទី៣
## អ្នកផ្គត់ផ្គង់/អ្នកទទួលការ

**ប្រការ៧ ._**

អ្នកផ្គត់ផ្គង់/អ្នកទទួលការ មានកាតព្វកិច្ចគោរពនិងអនុវត្តឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ និងសមស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។ អ្នកផ្គត់ផ្គង់/អ្នកទទួលការ មានភារកិច្ចជាអាទិ៍៖

- អនុវត្តឱ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព គំរូកាតាឡុក លក្ខណៈបច្ចេកទេស គំនូសប្លង់ ប្រតិទិនការងារ និងលក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងកិច្ចសន្យា
- ចាប់ផ្តើមនិងបញ្ចប់ការប្រគល់ទំនិញ/ការងារសំណង់/សេវាកម្ម តាមកាលកំណត់ដូចមានចែងក្នុងកិច្ចសន្យា
- មិនត្រូវចុះកិច្ចសន្យាបន្តទាំងស្រុង ទៅឱ្យភាគីទី៣ ណាមួយឡើយ
- ទទួលខុសត្រូវសងការខូចខាតដែលកើតចេញពីការអនុវត្តកិច្ចសន្យា
- សហការជាមួយស្ថាប័នអនុវត្តលទ្ធកម្ម និង/ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពេលចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចសន្យា
- រៀបចំនិងផ្តល់របាយការណ៍ និង/ឬឯកសារពាក់ព័ន្ធការត្រួតពិនិត្យគុណភាពនិងលក្ខណៈបច្ចេកទេសទំនិញ ដើម្បីធានាថា ទំនិញដែលត្រូវផ្គត់ផ្គង់ត្រឹមត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា (សម្រាប់ទំនិញដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ) ជូនស្ថាប័នអនុវត្តលទ្ធកម្ម
- រៀបចំនិងផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាការងារសំណង់/ការផ្តល់សេវាកម្មជូនស្ថាប័នអនុវត្តលទ្ធកម្ម។

## ផ្នែកទី៤
## អ្នកត្រួតពិនិត្យបច្ចេកទេស

**ប្រការ៨ ._**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំឱ្យមានអ្នកត្រួតពិនិត្យបច្ចេកទេស។ អ្នកត្រួតពិនិត្យបច្ចេកទេស អាចជាវិស្វករ មន្ត្រីបច្ចេកទេស ឬក្រុមបច្ចេកទេស។ អ្នកត្រួតពិនិត្យបច្ចេកទេស មានភារកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឱ្យបានត្រឹមត្រូវនិងសមស្របតាមលក្ខខណ្ឌនិងលក្ខណៈបច្ចេកទេសដូចមានចែងក្នុងកិច្ចសន្យា។ អ្នកត្រួតពិនិត្យបច្ចេកទេស មានភារកិច្ចជាអាទិ៍៖

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃឱ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព គំរូកាតាឡុក លក្ខណៈបច្ចេកទេស គំនូសប្លង់ ប្រតិទិនការងារ និងលក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងកិច្ចសន្យា
- ផ្តល់ការណែនាំបច្ចេកទេសដល់អ្នកបច្ចេកទេសរបស់អ្នកផ្គត់ផ្គង់/អ្នកទទួលការឱ្យអនុវត្តបានត្រឹមត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា
- បញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍និង/ឬឯកសារពាក់ព័ន្ធការត្រួតពិនិត្យគុណភាពនិងលក្ខណៈបច្ចេកទេសទំនិញ ដែលរៀបចំដោយអ្នកផ្គត់ផ្គង់ និងផ្តល់របាយការណ៍បញ្ជាក់នេះជូនគណៈកម្មការប្រគល់ទទួល (សម្រាប់ទំនិញដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ)
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាឱ្យបានទៀងទាត់តាមកម្មវិធីការងារនៃតារាងប្រតិទិនការងារ ឬតាមលក្ខខណ្ឌទូទាត់នៃកិច្ចសន្យា ដើម្បីជាមូលដ្ឋាន ជូនគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ក្នុងការត្រួតពិនិត្យវាយតម្លៃលទ្ធផលប្រគល់ទទួលការងារ និងប្រគល់ទទួលបញ្ចប់សុពលភាពធានាគុណភាពសំណង់ ជូនស្ថាប័នអនុវត្តលទ្ធកម្ម។

## ជំពូកទី៣
## ការកែប្រែលក្ខខណ្ឌនៃកិច្ចសន្យា

### ផ្នែកទី១
### ការកែប្រែលក្ខណៈបច្ចេកទេសទំនិញ/សេវាកម្ម ឬបទដ្ឋានបច្ចេកទេសសំណង់

**ប្រការ៩ ._**

ការកែប្រែលក្ខណៈបច្ចេកទេសទំនិញ/សេវាកម្ម ឬបទដ្ឋានបច្ចេកទេសសំណង់ មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែការកែប្រែតិចតួចពាក់ព័ន្ធនឹងយថាប្រភេទបរិមាណទីតាំងឬរយៈពេលផ្គត់ផ្គង់(សម្រាប់ទំនិញ/សេវាកម្ម) និងទំហំ/ខ្នាត, បរិមាណការងារ, លក្ខណៈបច្ចេកទេស, គំនូសប្លង់/រចនាបថ, ការផ្លាស់ប្តូរទីតាំង ឬរយៈពេលអនុវត្តការងារ(សម្រាប់សំណង់) ហើយការកែប្រែទាំងនោះមិនប៉ះពាល់ដល់គុណភាពទំនិញ សំណង់ និងសេវាកម្ម និងតម្លៃនៃកិច្ចសន្យាដើមឡើយ។

រាល់ការស្នើសុំកែប្រែយថាប្រភេទ, បរិមាណ, ទីតាំង ឬរយៈពេលផ្គត់ផ្គង់ សម្រាប់កិច្ចសន្យាទំនិញ/សេវាកម្ម ត្រូវភ្ជាប់មកជាមួយនូវតារាងស្នើសុំកែប្រែទាំងនោះ។ ចំពោះការស្នើសុំកែប្រែសម្រាប់កិច្ចសន្យាសំណង់ ត្រូវភ្ជាប់មកជាមួយនូវតារាងប្រៀបធៀប និងឧបសម្ព័ន្ធពាក់ព័ន្ធនឹងការស្នើសុំកែប្រែទាំងនោះ ធៀបជាមួយនឹងកិច្ចសន្យាដើម។ ឯកសារកែប្រែនេះនឹងក្លាយជាឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា។

ការកែប្រែសម្រាប់កិច្ចសន្យាទំនិញ សំណង់ និងសេវាកម្ម ដែលស្ថិតក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវស្នើសុំការពិនិត្យនិងសម្រេចត្រឹមសាមីស្ថាប័នអនុវត្តលទ្ធកម្ម ។ ករណីនេះ សាមីស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចម្លងជូនសេចក្តីសម្រេចពីការអនុញ្ញាតឱ្យកែប្រែមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់។

ដោយឡែក ការកែប្រែសម្រាប់កិច្ចសន្យាទំនិញ សំណង់ និងសេវាកម្ម ដែលមានការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ផ្នែកទី២
### ការកែប្រែតម្លៃកិច្ចសន្យា

**ប្រការ១០ ._**

ជាទូទៅ តម្លៃកិច្ចសន្យាគឺជាតម្លៃថេរក្នុងអំឡុងអនុវត្តកិច្ចសន្យា លើកលែងតែក្នុងកាលៈទេសៈពិសេសដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកិច្ចសន្យា ដោយសារការប្រែប្រួលខ្លាំងនៃតម្លៃទីផ្សារលើមុខទំនិញនិងមុខចំណាយពាក់ព័ន្ធសំខាន់ៗមួយចំនួនក្នុងកិច្ចសន្យា នោះតម្លៃកិច្ចសន្យាអាចកែប្រែបាន។ ការកែប្រែតម្លៃកិច្ចសន្យា អាចអនុញ្ញាតបានចំពោះទំនិញ/សំណង់/សេវាកម្មក្នុងកិច្ចសន្យាដែលមិនទាន់បានប្រគល់ទទួល/មិនទាន់បានអនុវត្តរួចប៉ុណ្ណោះ។

**ប្រការ១១ ._**

កាលៈទេសៈពិសេសដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកិច្ចសន្យា រួមមាន៖

- វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបង្កឱ្យមានការប្រែប្រួលខ្លាំងនៃតម្លៃទីផ្សារលើមុខទំនិញនិងមុខចំណាយពាក់ព័ន្ធសំខាន់ៗផ្សេងទៀត

- ប្រធានស័ក្តិ មានជាអាទិ៍៖ គ្រោះមហន្តរាយធម្មជាតិ, ជំងឺរាតត្បាត, អគ្គិភ័យ, ការហ៊ុមព័ទ្ធសេដ្ឋកិច្ច, កុបកម្ម, ការរាំងខ្ទប់, និងភាពចលាចលខាងនយោបាយ ឬសង្គ្រាម។

**ប្រការ១២ ._**

ការកែប្រែតម្លៃកិច្ចសន្យាក្នុងកាលៈទេសៈពិសេសដូចមានចែងក្នុងប្រការ១១ខាងលើ អាចធ្វើឡើងបាន តែក្នុងករណីដែលតម្លៃទីផ្សារលើមុខទំនិញនិងមុខចំណាយពាក់ព័ន្ធសំខាន់ៗ បានកើនឡើងលើសពី១០% នៃតម្លៃឯកត្តានៃមុខទំនិញក្នុងកិច្ចសន្យាដើម និងត្រូវមានភ្ជាប់ឯកសារភស្តុតាងបង្ហាញពីការកើនឡើងនៃតម្លៃទំនិញលើទីផ្សារដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

**ប្រការ១៣ ._**

រាល់ការស្នើសុំកែប្រែតម្លៃកិច្ចសន្យា ស្ថាប័នអនុវត្តលទ្ធកម្មដែលជាភាគីអ្នកទិញ/អ្នកម្ចាស់ការ ត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមការស្នើសុំរបស់អ្នកផ្គត់ផ្គង់/អ្នកទទួលការ។

ការស្នើសុំកែប្រែតម្លៃកិច្ចសន្យា ត្រូវបញ្ជាក់ពីតម្លៃទឹកប្រាក់ស្នើសុំកែប្រែនិងភស្តុតាងបង្ហាញពីការកើនឡើងនៃតម្លៃមុខទំនិញនិងមុខចំណាយពាក់ព័ន្ធសំខាន់ៗក្នុងកិច្ចសន្យា ដោយត្រូវភ្ជាប់តារាងប្រៀបធៀបតម្លៃប្រែប្រួលនៃមុខទំនិញនិងមុខចំណាយពាក់ព័ន្ធសំខាន់ៗជាឧបសម្ព័ន្ធ។

**ប្រការ១៤ ._**

រូបមន្តសម្រាប់គណនាការកែប្រែតម្លៃកិច្ចសន្យា មានដូចខាងក្រោម៖

$$P_{adjusted} = P_{base} + \Delta P$$

ដែល

$$\Delta P = \sum (Q_i \, x(C_{i,new} - C_{i,base}))$$

- $P_{adjusted}$ = តម្លៃកែប្រែនៃកិច្ចសន្យា
- $P_{base}$ = តម្លៃកិច្ចសន្យាដើម
- $Q_i$ = បរិមាណការងារ(សម្ភារៈ+ពលកម្ម) $i$ មានក្នុងកិច្ចសន្យាដើម
- $C_{i,new}$ = បរិមាណការងារបច្ចុប្បន្នកម្ម(សម្ភារៈ+ពលកម្ម) $i$
- $C_{i,base}$ = បរិមាណការងារដើម $i$

## ផ្នែកទី៣
## ការលុបកិច្ចសន្យា

**ប្រការ១៥ ._**

ស្ថាប័នអនុវត្តលទ្ធកម្ម អាចពិចារណាលុបកិច្ចសន្យាទាំងមូលឬផ្នែកខ្លះ ក្នុងករណីអ្នកផ្គត់ផ្គង់/អ្នកទទួលការស្ថិតក្នុងកាលៈទេសៈណាមួយដូចខាងក្រោម៖

១.អលទ្ធភាពក្នុងការប្រគល់ទំនិញ សំណង់ និងសេវាកម្ម តាមកាលកំណត់នៃកិច្ចសន្យា។

២.មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា។

៣.មិនបានចាត់វិធានការកែតម្រូវលើកំហុសឆ្គងឬសងការខូចខាត បន្ទាប់ពីទទួលបានការជូនដំណឹងពីស្ថាប័នអនុវត្តលទ្ធកម្ម។

៤.បោះបង់កិច្ចសន្យា ឬពន្យារពេលអនុវត្តកិច្ចសន្យា លើសពី៦០ថ្ងៃ។

៥.ក្ស័យធនឬស្ថិតក្នុងស្ថានភាពក្ស័យធន។

**ប្រការ១៦ ._**

ប្រសិនបើអ្នកផ្គត់ផ្គង់/អ្នកទទួលការ មិនអាចអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា ដោយសារករណីប្រធានស័ក្តិ នោះអ្នកផ្គត់ផ្គង់/អ្នកទទួលការត្រូវជូនដំណឹងជាបន្ទាន់ទៅស្ថាប័នអនុវត្តលទ្ធកម្ម។ អ្នកផ្គត់ផ្គង់/អ្នកទទួលការ ត្រូវផ្អាកឬបញ្ឈប់ការអនុវត្តកិច្ចសន្យាបន្ទាប់ពីមានការឯកភាពពីស្ថាប័នអនុវត្តលទ្ធកម្ម។ ប្រសិនបើប្រធានស័ក្តិបន្តរហូតដល់រយៈពេល៦០(ហុកសិប)ថ្ងៃ នោះអ្នកផ្គត់ផ្គង់/អ្នកទទួលការ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីលុបកិច្ចសន្យាតែម្តង។ ករណីនេះ ការទូទាត់ជូនអ្នកផ្គត់ផ្គង់/អ្នកទទួលការផ្អែកតាមលទ្ធផលដែលសម្រេចបានដោយមានកំណត់ហេតុត្រួតពិនិត្យវាយតម្លៃច្បាស់លាស់ និងត្រឹមត្រូវរបស់គណៈកម្មការប្រគល់ទទួល។

ការលុបកិច្ចសន្យាដែលពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការគ្រប់គ្រងការប្រគល់ទទួល

**ប្រការ១៧ ._**

ការប្រគល់ទទួលទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងតាមរយៈយន្តការដែលមានស្រាប់ រួមមានតំណាងគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម អង្គភាពលទ្ធកម្ម អ្នកផ្គត់ផ្គង់/អ្នកទទួលការ និងតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមានកំណត់ហេតុប្រគល់ទទួលច្បាស់លាស់ដោយមានការយល់ព្រមពីប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ដែលជាមូលដ្ឋានសម្រាប់ការទូទាត់។

ការប្រគល់ទទួលទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា។ ការប្រគល់ទទួលទំនិញ ត្រូវពិនិត្យឱ្យបានហ្មត់ចត់និងត្រឹមត្រូវតាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស ប៉ាន់គំរូ កាតាឡុក ដូចមានចែងក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស ដែលជាឧបសម្ព័ន្ធភ្ជាប់នៃកិច្ចសន្យា។ ចំពោះការប្រគល់ទទួលសំណង់ ត្រូវពិនិត្យឱ្យបានហ្មត់ចត់និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ទំហំ/ខ្នាត បរិមាណ គុណភាព ទម្រង់ គំនូសប្លង់/រចនាបថ និងភាពត្រឹមត្រូវនៃទីតាំងសំណង់។ រីឯ ការប្រគល់ទទួលសេវាកម្មវិញ ត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់និងត្រឹមត្រូវលើលទ្ធផលនៃការផ្តល់សេវាកម្ម ដូចមានចែងក្នុងកិច្ចសន្យា។

ការប្រគល់ទទួលលើកិច្ចសន្យាដែលមានការសម្រេចចុងក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៨ ._**

ការធានាគុណភាពទំនិញ ត្រូវអនុវត្តចំពោះប្រភេទនិងមុខទំនិញទាំងឡាយណាដែលមានការធានាពីប្រភពដើមនៃរោងចក្រ/ក្រុមហ៊ុន/សហគ្រាសផលិតប៉ុណ្ណោះ។ អ្នកផ្គត់ផ្គង់ ត្រូវធានាគុណភាពទំនិញ ស្របតាមតារាងតម្លៃនិងលក្ខណៈបច្ចេកទេសដែលជាឧបសម្ព័ន្ធនៃកិច្ចសន្យា។ ចំពោះការធានាគុណភាពសំណង់ ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ការងារ១០០% ស្របតាមរយៈពេលធានាគុណភាពសំណង់ជាស្ថាពរ ដូចមានចែងក្នុងកិច្ចសន្យា។ ក្នុងអំឡុងការធានាគុណភាពទំនិញ សំណង់ ក្នុងករណីពិនិត្យឃើញមានលក្ខណៈមិនប្រក្រតីដែលបណ្តាលមកពីកង្វះបទដ្ឋានបច្ចេកទេស នោះស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកផ្គត់ផ្គង់/អ្នកទទួលការឱ្យធ្វើការជួសជុលឬសាងសង់ឡើងវិញ ហើយរាល់ការចំណាយលើការជួសជុលឬសាងសង់នេះ ជាបន្ទុករបស់អ្នកផ្គត់ផ្គង់/អ្នកទទួលការ។ ប្រសិនបើលក្ខណៈមិនប្រក្រតីទាំងនេះបណ្តាលមកពីប្រធានស័ក្តិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលឡើងវិញជាបន្ទុករបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

## ជំពូកទី៥
## ការដោះស្រាយវិវាទក្នុងកិច្ចសន្យា

**ប្រការ១៩ ._**

ក្នុងអំឡុងអនុវត្តកិច្ចសន្យា ប្រសិនបើមានវិវាទណាមួយកើតឡើងពាក់ព័ន្ធនឹងការបកស្រាយកិច្ចសន្យា ឬការអនុវត្តកិច្ចសន្យា ភាគីនៃកិច្ចសន្យាត្រូវខិតខំដោះស្រាយវិវាទនោះតាមមធ្យោបាយចរចាដែលដឹកនាំ និងសម្របសម្រួលដោយប្រធានគម្រោង និងគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម។

ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេល១៤(ដប់បួន)ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមការចរចាដោះស្រាយវិវាទ នោះភាគីនៃកិច្ចសន្យាត្រូវដោះស្រាយវិវាទនោះតាមរយៈការសម្រុះសម្រួលដោយយន្តការឯករាជ្យ។ ការជ្រើសរើសអ្នកសម្រុះសម្រួលឯករាជ្យ ត្រូវមានការយល់ព្រមពីភាគីនៃកិច្ចសន្យា។ ថ្លៃសេវានិងការចំណាយពាក់ព័ន្ធនឹងការសម្រុះសម្រួលវិវាទ ត្រូវទទួលរ៉ាប់រងដោយភាគីនៃកិច្ចសន្យាដោយចំណែកស្មើគ្នា។

ក្នុងករណី ភាគីនៃកិច្ចសន្យាមិនសម្រេចបានកិច្ចព្រមព្រៀងតាមការសម្រុះសម្រួល ដោយយន្តការឯករាជ្យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ នោះទេ ភាគីនៃកិច្ចសន្យាមានសិទ្ធិបន្តស្វែងរកដំណោះស្រាយ តាមរយៈ យន្តការមជ្ឈត្តការជាតិ ដែលយល់ព្រមពីភាគីនៃកិច្ចសន្យា ឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ២០ ._**

ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ និងប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២១ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- ដូចប្រការ ២១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០២៦.១១៣ ប្រ.ក

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 1112
ថ្ងៃទី 26 ខែ 02 ឆ្នាំ 26
ម៉ោង 2 H 37

## ប្រកាស
## ស្តីពី
## លក្ខខណ្ឌសម្រាប់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៧.០១៧.៣៤៤ ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែមិន
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ដែលធ្វើប្រតិបត្តិការទិញនិងគ្រប់គ្រងឥណទានមិនដំណើរការ និងទ្រព្យធានារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ឥណទានមិនដំណើរការ** (Non-Performing Loans) សំដៅដល់ឥណទានដែលត្រូវបានចាត់ថ្នាក់ "ក្រោមស្តង់ដារ" "សង្ស័យ" ឬ "បាត់បង់" ស្របតាមប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមកែរមិន។
- **គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម** (Asset Management Institution) សំដៅដល់គ្រឹះស្ថានដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការស្របតាមក្របខ័ណ្ឌបទប្បញ្ញត្តិនៃប្រកាសនេះ។
- **ការគ្រប់គ្រងឥណទានមិនដំណើរការ** (Non-Performing Loan Management) សំដៅដល់ដំណើរការចាត់ចែងឥណទានមិនដំណើរការតាមរយៈវិធីសាស្ត្រផ្សេងៗ រួមមាន ការប្រមូលបំណុលត្រលប់មកវិញ ការផ្ទេរ ការបំប្លែងបំណុលទៅជាភាគហ៊ុន ការរៀបចំឥណទានឡើងវិញ ឬមធ្យោបាយផ្សេងៗទៀតដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា។
- **ទ្រព្យធានាភ្ជាប់** (Associated Collateral) សំដៅដល់ទ្រព្យសកម្ម ឬសិទ្ធិផ្សេងទៀតដែលភ្ជាប់ទៅនឹងឥណទានមិនដំណើរការ រួមមាន អចលនវត្ថុ ចលនវត្ថុ ទ្រព្យសកម្មផ្សេងទៀត ជាដើម ទោះជាទ្រព្យទាំងនោះកាន់កាប់ដោយកូនបំណុល ឬដោយតតិយជនដែលពាក់ព័ន្ធក៏ដោយ។
- **ក្រុមប្រឹក្សាភិបាល** (Board of Director) សំដៅដល់បុគ្គលមួយក្រុមដែលមានអភិបាលជាសមាជិកទទួលខុសត្រូវត្រួតពិនិត្យលើការគ្រប់គ្រង និងប្រតិបត្តិការរបស់គ្រឹះស្ថានក្នុងនាមភាគទុនិក។
- **គណៈគ្រប់គ្រងជាន់ខ្ពស់** (Senior Management) សំដៅដល់គណៈគ្រប់គ្រងប្រតិបត្តិរបស់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ដែលមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះក្រុមប្រឹក្សាភិបាលសម្រាប់ដំណើរការគ្រប់គ្រងប្រចាំថ្ងៃឱ្យបានល្អនិងប្រកបដោយភាពប្រុងប្រយ័ត្ន ដែលជាទូទៅរួមមាន ថ្នាក់ដឹកនាំជាន់ខ្ពស់ ឬតំណែងដែលមានកម្រិតស្មើ និងប្រធាននាយកដ្ឋាន ឬតំណែងដែលមានកម្រិតស្មើដូចជា ប្រធានមុខងារប្រតិបត្តិតាម និងប្រធានសវនកម្មផ្ទៃក្នុង។

## ជំពូកទី ២
## សកម្មភាពអាជីវកម្ម

**ប្រការ ៤.- សកម្មភាពអនុញ្ញាត**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា អាចធ្វើសកម្មភាពអាជីវកម្ម ដូចខាងក្រោម៖

- ទិញ និងគ្រប់គ្រងឥណទានមិនដំណើរការ ព្រមទាំងទ្រព្យធានាភ្ជាប់ ពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- ទិញ និងគ្រប់គ្រងអចលនទ្រព្យពីកូនបំណុលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយអចលនទ្រព្យនេះ ត្រូវបានដាក់លក់តាមរយៈការប្រកាសដេញថ្លៃដោយតុលាការ ឬតាមរយៈអភិបាលបណ្តោះអាសន្ន ឬដំណើរការជម្រះបញ្ជី

- ផ្ដល់សេវាប្រមូលបំណុលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- សម្របសម្រួលលក់ទ្រព្យធានាភ្ជាប់ ដោយមានការយល់ព្រមពីកូនបំណុល
- លក់ឥណទានទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មផ្សេងទៀត និង
- សកម្មភាពអាជីវកម្មផ្សេងទៀតដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥.- សកម្មភាពហាមឃាត់**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម មិនត្រូវ៖

- ផ្ដល់ឥណទាន ឬបុនហិរញ្ញប្បទាន
- ធានាលើឥណទាន
- ទិញឥណទានមិនដំណើរការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្ដល់កម្ចីដោយផ្ទាល់ ឬប្រយោលឱ្យខ្លួន និង
- ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀតដែលហាមឃាត់ដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៣
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

**ប្រការ ៦.- ទម្រង់នៃគ្រឹះស្ថាន**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវចុះបញ្ជីក្នុងទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

**ប្រការ ៧.- ដើមទុនចុះបញ្ជីអប្បបរមា**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀលគត់)។

**ប្រការ ៨.- ពាក្យស្នើសុំអាជ្ញាបណ្ណ**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មពីធនាគារជាតិនៃកម្ពុជាត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចខាងក្រោម៖

១. នាម ឬនាមករណ៍អាជីវកម្ម និងអាសយដ្ឋាន ដែលបានចុះបញ្ជី
២. ភស្តុតាងបញ្ជាក់ពីចំនួនដើមទុន និងប្រភពទុន
៣. ឯកសារគតិយុត្ត លក្ខន្តិកៈ និងឯកសារផ្សេងទៀត
៤. រចនាសម្ព័ន្ធគ្រប់គ្រង
៥. អត្តសញ្ញាណរបស់ភាគទុនិក និងទំហំភាគហ៊ុនដែលបានកាន់កាប់ដោយភាគទុនិក និងភស្តុតាងបញ្ជាក់ពីសមត្ថភាព បទពិសោធ និងលក្ខណៈវិនិច្ឆ័យសមស្របលើការងារគ្រប់គ្រងអាជីវកម្ម
៦. អត្តសញ្ញាណរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ព្រមទាំងភស្តុតាងដែលបញ្ជាក់ថាបុគ្គលនោះមានកេរ្តិ៍ឈ្មោះល្អ គុណវុឌ្ឍិ និងបទពិសោធគ្រប់គ្រាន់ក្នុងការដោះស្រាយឥណទានមិនដំណើរការ

៧. ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ ដំបូង និងយុទ្ធសាស្ត្រដើម្បីធ្វើអាជីវកម្មប្រកបដោយចីរភាព

៨. ផែនការទិញ គ្រប់គ្រង និងយុទ្ធសាស្ត្រចាត់ចែងឥណទានមិនដំណើរការ

៩. ពិពណ៌នាពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ដំណើរការអាជីវកម្មប្រកបដោយសុវត្ថិភាព

១០. គោលការណ៍ស្តីពី ការដោះស្រាយបណ្តឹងអតិថិជន និង

១១. នីតិវិធីសវនកម្មផ្ទៃក្នុង។

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មផ្តល់ឯកសារពាក់ព័ន្ធចាំបាច់ផ្សេងទៀត សម្រាប់ការវាយតម្លៃលើពាក្យស្នើសុំ។

**ប្រការ ៩.- ការកាន់កាប់ភាគហ៊ុនដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបំណងទិញ ឬកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៤
## ការផ្តល់អាជ្ញាបណ្ណ និងសោហ៊ុយពាក់ព័ន្ធ

**ប្រការ ១០.- ការពិនិត្យពាក្យស្នើសុំ និងការផ្តល់អាជ្ញាបណ្ណ**

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ ចាប់ពីពេលទទួលបានពាក្យស្នើសុំពេញលេញ។

ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តក្នុងលិខិតយល់ព្រមជាគោលការណ៍។ ប្រសិនបើបុគ្គលដាក់ពាក្យស្នើសុំ មិនគោរពតាមលក្ខខណ្ឌនិងរយៈពេលកំណត់នោះទេ លិខិតយល់ព្រមជាគោលការណ៍នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេល និងយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា នឹងផ្តល់អាជ្ញាបណ្ណ បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតយល់ព្រមជាគោលការណ៍ និងនីតិវិធីពាក់ព័ន្ធទាំងអស់។

**ប្រការ ១១.- សុពលភាពនៃអាជ្ញាបណ្ណ**

អាជ្ញាបណ្ណមានសុពលភាពរយៈពេល ៥ (ប្រាំ) ឆ្នាំ និងអាចស្នើសុំបន្តជាថ្មីបាន។ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាព ក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនអាជ្ញាបណ្ណផុតសុពលភាព។

**ប្រការ ១២.- សំណើសុំផ្សេងៗ**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ក្នុងករណីណាមួយ ដូចខាងក្រោម៖

- ផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន
- បង្កើន ឬបន្ថយដើមទុនចុះបញ្ជី

- កែប្រែលក្ខន្តិកៈ
- ផ្លាស់ប្តូរក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រងជាន់ខ្ពស់ និង
- រួមបញ្ចូល ផ្ទេរ ឬលក់ដោយផ្នែក ឬទាំងស្រុងនៃភាគហ៊ុន ឬរាល់ការកែប្រែ និងបញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៣.- សោហ៊ុយអាជ្ញាបណ្ណ**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ៥០.០០០.០០០ រៀល (ហាសិបលានរៀលគត់) នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។ ចំពោះគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណ ដូចខាងក្រោម៖

- ឆមាសទី១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ឆមាសទី២ ៖ ត្រូវបង់មួយឆមាស។

**ប្រការ ១៤.- សោហ៊ុយផ្សេងៗ**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវបង់សោហ៊ុយផ្សេងៗទៀត ដូចខាងក្រោម៖

- ការសាកសួរព័ត៌មាន៖ ៥០០.០០០ រៀល (ប្រាំរយពាន់រៀលគត់)
- ការសិក្សាលើពាក្យសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ៖ ២.៥០០.០០០ រៀល (ពីរលានប្រាំរយពាន់រៀលគត់)
- ការកែប្រែលក្ខន្តិកៈ៖ ១.០០០.០០០ រៀល (មួយលានរៀលគត់) ក្នុង ១ (មួយ) ទំព័រ
- ការផ្លាស់ប្តូរអាជ្ញាបណ្ណ៖ ២.០០០.០០០ រៀល (ពីរលានរៀលគត់)
- ការផ្ទេរភាគហ៊ុន ឬការបង្កើនដើមទុន៖ ០,៥% (សូន្យក្បៀសប្រាំភាគរយ) នៃតម្លៃចារឹកភាគហ៊ុនដែលបានផ្ទេរ ឬបង្កើន និង
- ការបន្ថយដើមទុន៖ ១% (មួយភាគរយ) នៃតម្លៃចារឹកភាគហ៊ុនដែលបានបន្ថយ។

## ជំពូកទី ៥
## ការផ្ទេរឥណទានមិនដំណើរការ

**ប្រការ ១៥.- ការទិញឥណទានមិនដំណើរការ**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវទិញឥណទានមិនដំណើរការប្រកបដោយតម្លាភាព និងឯករាជ្យ ជាមួយតម្លៃព្រមព្រៀងរវាងគូភាគី។

**ប្រការ ១៦.- សិទ្ធិ និងភារកិច្ចរបស់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម**

នៅពេលទិញឥណទានមិនដំណើរការ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

១. សិទ្ធិក្នុងការអនុវត្តការទាមទារពីកូនបំណុល និងអ្នកធានាណាមួយ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន

២. សិទ្ធិទទួលបានទ្រព្យធានា និងសិទ្ធិប្រាតិភោគទាំងអស់ដែលពាក់ព័ន្ធនឹងឥណទានមិនដំណើរការដែលបានទិញ

៣. កាតព្វកិច្ចរាយការណ៍ព័ត៌មានឥណទានដូចមានកំណត់ក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន និង

៤. ការទទួលយកទាំងស្រុង នូវរាល់សិទ្ធិ កម្មសិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចទាំងឡាយរបស់ម្ចាស់បំណុល ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃការទិញ។

ក្នុងករណី គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម មានបំណងលក់ឥណទានទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មផ្សេងទៀត គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា អាចកំណត់នូវកាតព្វកិច្ចផ្សេងទៀត តាមការចាំបាច់។

**ប្រការ ១៧.- សិទ្ធិ និងកាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាលើការលក់ឥណទានមិនដំណើរការទៅគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ដោយភ្ជាប់នូវឯកសារ ដូចជា៖

១. លិខិតស្នើសុំការលក់ឥណទានមិនដំណើរការ

២. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

៣. ឯកសារវាយតម្លៃឥណទានមិនដំណើរការដែលត្រូវលក់ និង

៤. ឯកសារផ្សេងទៀតតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ទេរឯកសារឥណទានច្បាប់ដើមពាក់ព័ន្ធទាំងអស់ដែលមានដូចជា កិច្ចព្រមព្រៀងឥណទាន ឯកសារទ្រព្យធានា និងប្រវត្តិទូទាត់សង ទៅឱ្យគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម និងជូនដំណឹងជាផ្លូវការទៅអតិថិជន និងការិយាល័យចែករំលែកព័ត៌មានឥណទាន អំពីការផ្ទេរឥណទានមិនដំណើរការនេះ។

ធនាគារជាតិនៃកម្ពុជា អាចកំណត់នូវកាតព្វកិច្ចផ្សេងទៀត តាមការចាំបាច់។

**ប្រការ ១៨.- ការប្រមូលបំណុល**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវរៀបចំក្រមប្រតិបត្តិស្តីពី ការប្រមូលបំណុលដោយប្រកាន់ខ្ជាប់នូវបទដ្ឋានវិជ្ជាជីវៈ និងសុចរិតភាព ដែលរាល់សកម្មភាពទាំងអស់ត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការការពារអ្នកប្រើប្រាស់ ឯកជនភាពទិន្នន័យ និងការរក្សាការសម្ងាត់វិជ្ជាជីវៈ។ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវធានាថាបុគ្គលិកពាក់ព័ន្ធទាំងអស់ទទួលបានការបណ្តុះបណ្តាលក្រមប្រតិបត្តិនេះជាប្រចាំ។

**ប្រការ ១៩.- ការដោះស្រាយបណ្តឹងអតិថិជន**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវរៀបចំឱ្យមានយន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងអតិថិជន ដោយត្រូវអនុលោមតាមប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូកទី ៦
## វិធានប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ

### ប្រការ ២០.- ការតម្កល់ដើមទុនចុះបញ្ជី

មុនពេលចាប់ផ្ដើមធ្វើសកម្មភាពអាជីវកម្ម គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវបង់ដើមទុនចុះបញ្ជី ១០០% (មួយរយភាគរយ) ក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវតម្កល់ប្រាក់ ៥% (ប្រាំភាគរយ) នៃដើមទុនចុះបញ្ជី ដើម្បីធានាដើមទុន ក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

### ប្រការ ២១.- វិធានប្រុងប្រយ័ត្ន

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវអនុវត្តតាមវិធានប្រុងប្រយ័ត្ន ដែលនឹងកំណត់ក្នុងប្រកាសដោយឡែក។

### ប្រការ ២២.- កាតព្វកិច្ចរាយការណ៍

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវរៀបចំនិងផ្ញើរបាយការណ៍ ដូចខាងក្រោម៖

- របាយការណ៍ហិរញ្ញវត្ថុស្របតាមស្ដង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
- របាយការណ៍ស្ដីពី សំពៀតឥណទានមិនដំណើរការ និងដំណោះស្រាយ ដោយប្រើប្រាស់គំរូរបាយការណ៍ដូចមាននៅក្នុងបរិសិដ្ឋ និង
- របាយការណ៍ផ្សេងទៀតតាមការតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវផ្ញើរបាយការណ៍ទាំងនេះជារៀងរាល់ត្រីមាសមកធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែទីមួយនៃត្រីមាសបន្ទាប់។ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មត្រូវទទួលខុសត្រូវក្នុងការធានានូវភាពត្រឹមត្រូវនៃរបាយការណ៍ដែលបានផ្ញើមកធនាគារជាតិនៃកម្ពុជា។

ក្រៅពីរបាយការណ៍ខាងលើ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច ជូនធនាគារជាតិនៃកម្ពុជាមិនលើសពីថ្ងៃទី៣០ ខែមេសា នៃឆ្នាំបន្ទាប់។

### ប្រការ ២៣.- ការសម្ងាត់វិជ្ជាជីវៈ

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវអនុវត្តការសម្ងាត់វិជ្ជាជីវៈ ដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងរាល់បុគ្គលិកផ្សេងទៀតទាំងអស់របស់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម មិនត្រូវបញ្ចេញព័ត៌មានឬទិន្នន័យដែលមានចរិតសម្ងាត់ដែលបានដឹងតាមរយៈការបំពេញមុខងារ។
- បុគ្គលទាំងឡាយណាដែលមិនគោរពតាមកាតព្វកិច្ចទាក់ទងនឹងការរក្សាការសម្ងាត់វិជ្ជាជីវៈនេះ ត្រូវទទួលទោសតាមច្បាប់ស្ដីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- កាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈនេះ មិនអាចជំទាស់នឹងអាជ្ញាធរអាណាព្យាបាល ក្រុមហ៊ុនសវនកម្ម អភិបាលបណ្ដោះអាសន្ន អ្នកជម្រះបញ្ជី ក៏ដូចជាអាជ្ញាធរតុលាការដែលចាត់ការក្នុងក្របខ័ណ្ឌនៃនីតិព្រហ្មទណ្ឌ។

**ប្រការ ២៤.- ការរក្សាកំណត់ត្រា**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវរក្សាឯកសារពាក់ព័ន្ធការធ្វើប្រតិបត្តិការ កំណត់ត្រាគណនេយ្យនិងហិរញ្ញវត្ថុ និងកំណត់ត្រាប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា។ ឯកសារនិងកំណត់ត្រាទាំងនេះ ត្រូវរក្សាទុករយៈពេល ១០ (ដប់) ឆ្នាំ រាប់ចាប់ពីថ្ងៃបញ្ចប់ប្រតិបត្តិការដោះស្រាយឥណទានមិនដំណើរការ រួមទាំងទ្រព្យធានា។

**ប្រការ ២៥.- ការត្រួតពិនិត្យ**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា អាចចុះត្រួតពិនិត្យគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មដោយមាន ឬពុំមានការជូនដំណឹងជាមុន។

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវផ្តល់ឯកសារនិងកំណត់ត្រាតាមការស្នើសុំ សម្រាប់គោលបំណងត្រួតពិនិត្យ តាមពេលវេលាកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ចាត់វិធានការកែតម្រូវក្នុងករណីល្មើសនឹងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ជំពូកទី ៧
## អភិបាលកិច្ច

**ប្រការ ២៦.- សមាសភាពក្រុមប្រឹក្សាភិបាល**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មត្រូវមានសមាជិកក្រុមប្រឹក្សាភិបាលយ៉ាងតិចចំនួន ៥ (ប្រាំ) រូប ដែលក្នុងនោះមានសមាជិកឯករាជ្យយ៉ាងតិច ២ (ពីរ) រូប។

**ប្រការ ២៧.- គុណវុឌ្ឍិក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់**

សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់អំពីប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងយល់ដឹងពីបរិស្ថានច្បាប់និងបទប្បញ្ញត្តិដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើង។ គ្មានជនណាម្នាក់ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់នៃគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មឡើយ ប្រសិនបើជននោះត្រូវបានផ្តន្ទាទោសពីៈ

- បទឧក្រិដ្ឋណាមួយ
- បទលួច បទក្លែងបន្លំ ឬបទរំលោភលើសេចក្តីទុកចិត្ត
- ព្រឹទ្ធិកម្ម
- ការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ការចេញផ្សាយមូលប្បទានប័ត្រដែលគ្មាន ឬមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី និង
- ការក្ស័យធន ការដាក់ទ្រព្យសម្បត្តិក្រោមអភិបាលបណ្តោះអាសន្ន ឬការជម្រះបញ្ជីទ្រព្យសម្បត្តិ។

សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ដែលត្រូវតែងតាំង ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ២៨.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវអនុម័ត និងត្រួតពិនិត្យឡើងវិញជាប្រចាំនូវយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធី ពាក់ព័ន្ធនឹងប្រតិបត្តិការ និងការគ្រប់គ្រងហានិភ័យ។ ក្រុមប្រឹក្សាភិបាល ត្រូវធានាថា គោលនយោបាយ និងនីតិវិធី ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តផែនការសកម្មភាពអាជីវកម្ម និងត្រូវបង្កើតគណៈកម្មការសវនកម្ម គណៈកម្មការគ្រប់គ្រងហានិភ័យ និងគណៈកម្មការដែលផ្តោតលើការត្រួតពិនិត្យលើការទិញឥណទានមិនដំណើរការ។ ក្រុមប្រឹក្សាភិបាលក៏អាចបង្កើតគណៈកម្មការផ្សេងទៀតតាមការចាំបាច់ ឬតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ក្រុមប្រឹក្សាភិបាល ត្រូវបង្កើតឱ្យមានមុខងារប្រតិបត្តិតាម សវនកម្មផ្ទៃក្នុង និងផ្នែកច្បាប់ ដោយធានាថាផ្នែកទាំងពីរនេះមានធនធានមនុស្សគ្រប់គ្រាន់ និងមានគុណវុឌ្ឍិដើម្បីបំពេញតួនាទី។

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងហោចណាស់ ៤ (បួន) ដងក្នុង ១ (មួយ) ឆ្នាំ ហើយគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាជាមុននូវរបៀបវារៈនៃកិច្ចប្រជុំនីមួយៗ។ ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជា អាចចូលរួមក្នុងកិច្ចប្រជុំជាអ្នកអង្កេតការណ៍។

**ប្រការ ២៩.- ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងជាន់ខ្ពស់**

គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ នីតិវិធី ដំណើរការ និងប្រព័ន្ធសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងប្រតិបត្តិការអាជីវកម្ម ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ប្រការ ៣០.- សកម្មភាពរបស់តតិយភាគី**

នៅពេលគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម មានបំណងប្រើប្រាស់មុខងារប្រតិបត្តិការពីតតិយភាគី គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះរាល់សកម្មភាពរបស់ខ្លួន រួមទាំងសកម្មភាពរបស់តតិយភាគី។

**ប្រការ ៣១.- ទំនាស់ផលប្រយោជន៍**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវបង្កើតគោលនយោបាយសម្រាប់ទប់ស្កាត់ និងដោះស្រាយទំនាស់ផលប្រយោជន៍ ដើម្បីធានាថា រាល់សកម្មភាពទាំងអស់ត្រូវប្រព្រឹត្តទៅដោយយុត្តិធម៌ តម្លាភាព ស្មោះត្រង់ និងឯករាជ្យ។

**ប្រការ ៣២.- នីតិវិធីវិស្សលប្ល័វីង**

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវបង្កើតនីតិវិធីវិស្សលប្ល័វីង (Whistle Blowing Procedure) ដែលជានីតិវិធីសម្រាប់ដោះស្រាយស្ថានភាពទំនាស់ផលប្រយោជន៍ ឬការមិនប្រតិបត្តិតាម ដែលកើតមានក្នុងដំណើរការប្រតិបត្តិការជាប្រក្រតីតាមរយៈការដាក់ចេញនីតិវិធីនៃការរាយការណ៍ និង

បង្កើតយន្តការការពារចំពោះបុគ្គលិកដែលបំពេញភារកិច្ចដោយសុចរិត និងដើម្បីផលប្រយោជន៍របស់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មទាំងមូល។

គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម ត្រូវផ្សព្វផ្សាយដល់បុគ្គលិកឱ្យយល់ដឹងច្បាស់លាស់អំពីដំណើរការ និងនីតិវិធីវិស្សលប្លូវឹង។

## ជំពូកទី ៨
## ទណ្ឌកម្ម និងពិន័យ

### ប្រការ ៣៣.- ទណ្ឌកម្មខាងវិន័យ

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ប្រការ ៣៤.- ពិន័យ

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជាអាចនឹងដាក់ពិន័យ ដូចខាងក្រោម៖

១. គ្រឹះស្ថានដែលមិនគោរពតាមបញ្ញត្តិដូចមានកំណត់ក្នុងប្រការ ២២ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀលគត់) ក្នុង ១ (មួយ) ថ្ងៃ។

២. គ្រឹះស្ថានដែលល្មើសនឹងបញ្ញត្តិផ្សេងៗទៀតក្រៅពីចំណុច (១) នៃប្រការនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ ចំនួន ៣.០០០.០០០ រៀល (បីលានរៀលគត់) ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យកែតម្រូវផុតកំណត់។

៣. គ្រឹះស្ថានដែលមិនគោរពតាមអធិបញ្ញា និង/ឬ ល្មើសបទប្បញ្ញត្តិជាធរមាននឹងត្រូវរងពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀលគត់) ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

### ប្រការ ៣៥.- ការផ្អាក ឬដកហូតអាជ្ញាបណ្ណ

ធនាគារជាតិនៃកម្ពុជា អាចផ្អាក ឬដកហូតអាជ្ញាបណ្ណ ប្រសិនបើគ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម៖

- មិនចាប់ផ្តើមអាជីវកម្មរបស់ខ្លួនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណ
- ល្មើសច្បាប់ ឬបទប្បញ្ញត្តិ
- អសាធនភាព ឬ
- ស្នើសុំបញ្ឈប់ប្រតិបត្តិការដោយស្ម័គ្រចិត្ត។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

### ប្រការ ៣៦.- ការអនុវត្ត

អគ្គលេខាធិការ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមាន

ការពាក់ព័ន្ធ គ្រឹះស្ថានគ្រប់គ្រងទ្រព្យសម្ទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៣៧.- ប្រសិទ្ធភាព**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល៖**
- ដូចប្រការ ៣៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# បរិសិដ្ឋ

## របាយការណ៍ស្តីពី សំពៀតឥណទានមិនដំណើរការ និងដំណោះស្រាយ

## Report on NPLs Portfolio and Recovery

| | |
|---|---|
| លេខសម្គាល់របាយការណ៍<br>Report ID | |
| ជំនាន់របាយការណ៍<br>Report Version | |
| កាលបរិច្ឆេទ<br>As at | |
| ឈ្មោះគ្រឹះស្ថាន<br>Institution's Name | |
| អត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាមេរិក = X រៀល<br>Exchange Rate 1 USD = X Riel | |
| ឯកតាគិតជាលានរៀល<br>In million Riels | |

| ល.រ No. | ឈ្មោះកូនបំណុល Name of debtor | គ្រឹះស្ថានដើម Originated Institution | ប្រភេទនៃឥណទាន Type of Loan | សមតុល្យឥណទានមិនដំណើរការដែលបានទិញពីគ្រឹះស្ថាន NPLs Purchased Balance | តម្លៃទិញឥណទានមិនដំណើរការពីគ្រឹះស្ថាន NPLs Purchased Price | ប្រភេទនៃទ្រព្យធានា Type of Collateral | តម្លៃទ្រព្យធានា Collateral Value | ចំនួនប្រាក់ដែលប្រមូលបាន Recovered Amount | វិធីសាស្ត្រនៃការប្រមូលប្រាក់ Recovery Method | ស្ថានភាពនៃការប្រមូលប្រាក់ Recovery Status | ផ្សេងៗ Remark |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| 3 | | | | | | | | | | | |
| 4 | | | | | | | | | | | |
| 5 | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ ០០៩ ឯក.ក៣៦

# ប្រកាស
# ស្ដីពី
# ការបង្កើតស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាល ទាំង៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្ដូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣០៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៣២ មាត្រា៣៦ និងមាត្រា៤០ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ និងមាត្រា១៣ថ្មី នៃអនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងប្រកាសលេខ ០៤៤ ប្រក. ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការ[illegible]ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសេចក្ដីត្រូវការចាំបាច់ របស់សាកលវិទ្យាល័យការពារជាតិ

## សម្រេច

**ប្រការ១ .-**

ត្រូវបានរៀបចំស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាល ទាំង៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ ដូចខាងក្រោម៖

### ១. រូបភាពរបស់ស្លាកសញ្ញាសម្គាល់

### ១.១. វគ្គបណ្តុះបណ្តាលជំនាញការពារជាតិ

- ស្លាកសញ្ញាមានរាងចតុកោណស្មើ ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើមានរូបមកុដ និងមានសរសេរអក្សរ "**យុទ្ធសាស្ត្រការពារជាតិ**" ពីក្រោមពណ៌មាស
- នៅចំកណ្តាលផ្នែកខាងក្រោយ មានរូបស្លាបសត្វអមសងខាង យុថ្កា និងផ្លែលំពែងត្រីសូល៍ ពណ៌មាស
- ផ្នែកខាងមុខ មានរូបសៀវភៅបើក ពណ៌ស និងមានលេខសម្គាល់ជំនាន់វគ្គបណ្តុះបណ្តាលត្រូវផ្លាស់ប្តូរតាមជំនាន់នីមួយៗ ពណ៌មាស។

### ១.២. វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា

- ស្លាកសញ្ញាមានរាងខែល ផ្ទៃពណ៌ខៀវផ្ទៃមេឃ និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស
- ចំកណ្តាលមានរង្វង់មូល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- ក្នុងរង្វង់ផ្នែកខាងលើមានមកុដ ពណ៌មាស រូបសៀវភៅបើក ពណ៌ស មានកួរស្រូវកោងរាងស្នែងក្របីសងខាង ពណ៌មាស
- នៅកណ្តាលសៀវភៅបើក មានលេខសម្គាល់ជំនាន់វគ្គបណ្តុះបណ្តាលត្រូវផ្លាស់ប្តូរតាមជំនាន់នីមួយៗ ពណ៌មាស
- នៅក្រោមសៀវភៅខាងក្រោយ មានរូបយុថ្កា ស្លាបសត្វត្រដាង ខាងមុខមានរូបកាំភ្លើង២ខ្វែងគ្នាពណ៌មាស
- ផ្នែកខាងក្រោមមានសរសេរអក្សរ "**បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រយោធា**" ពណ៌មាស។

### ១.៣. វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រនយោបាយ

- ស្លាកសញ្ញាមានរាងជាខែល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស
- ចំកណ្តាលស្លាកសញ្ញាមានរូបភាពដូច **ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រយោធា**
- ផ្នែកខាងក្រោម មានសរសេរអក្សរ "**បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រនយោបាយ**" ពណ៌មាស។

### ១.៤. វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រព័ត៌មានវិទ្យា

- ស្លាកសញ្ញាមានរាងជាខែល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស

- ចំកណ្ដាលស្លាកសញ្ញាមានរង្វង់មូល ផ្ទៃពណ៌ខៀវផ្ទៃមេឃ និងមានរូបភាពដូច ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា មានបន្ថែមរូបប្រព័ន្ធព័ត៌មានវិទ្យាពណ៌ខៀវផ្ទៃមេឃនៅខាងមុខរូបយុថ្កា
- នៅក្នុងរូបប្រព័ន្ធព័ត៌មានវិទ្យាមានសរសេរអក្សរ "**ម.ព.វ**" ជាអក្សរកាត់ "**មហាវិទ្យាល័យព័ត៌មានវិទ្យា**" ពណ៌មាស
- ផ្នែកខាងក្រោមមានសរសេរអក្សរ "**បរិញ្ញាបត្រព័ត៌មានវិទ្យា**" ពណ៌មាស។

**១.៥. វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រកស្តុភារយោធា**

- ស្លាកសញ្ញាមានរាងជាខែល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជាបញ្ឈិតចុះក្រោម និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស
- កណ្ដាលស្លាកសញ្ញាមានរូបភាពដូច ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា មានបន្ថែមរូបសញ្ញាជំនាញភស្តុភារ ពណ៌មាស នៅខាងមុខរូបយុថ្កា
- នៅក្នុងសញ្ញាជំនាញភស្តុភារមានសរសេរអក្សរ "**ភ.យ**" ជាអក្សរកាត់ "**ភស្តុភារយោធា**" ពណ៌ក្រហម
- ផ្នែកខាងក្រោមមានសរសេរអក្សរ "**បរិញ្ញាបត្រភស្តុភារយោធា**" ពណ៌មាស។

**១.៦. វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រហិរញ្ញវត្ថុយោធា**

មានរូបភាពដូច ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលជំនាញភស្តុភារយោធា ខុសគ្នាត្រង់៖

- នៅក្នុងសញ្ញាជំនាញភស្តុភារមានសរសេរអក្សរ "**ហ.យ**" ជាអក្សរកាត់ "**ហិរញ្ញវត្ថុយោធា**" ពណ៌ក្រហម
- ផ្នែកខាងក្រោមមានសរសេរអក្សរ "**បរិញ្ញាបត្រហិរញ្ញវត្ថុយោធា**" ពណ៌មាស។

**១.៧. វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រអប់រំចិត្តសាស្ត្រយោធា**

- ស្លាកសញ្ញាមានរាងជាខែល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស
- ចំកណ្ដាលស្លាកសញ្ញាមានរូបភាពដូច ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា
- ផ្នែកខាងក្រោម មានសរសេរអក្សរ "**បរិញ្ញាបត្រអប់រំចិត្តសាស្ត្រយោធា**" ពណ៌មាស។

**១.៨. វគ្គបណ្ដុះបណ្ដាលគរុកោសល្យយោធាចារ្យ**

- ស្លាកសញ្ញាមានរាងជាខែល ផ្ទៃពណ៌ខៀវ ក្រហម ដូចទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា បញ្ឈរ និងមានរឹមព័ទ្ធជុំវិញពណ៌មាស
- ផ្នែកខាងលើសរសេរអក្សរ "**សាកលវិទ្យាល័យការពារជាតិ**" ពណ៌មាស
- ចំកណ្ដាលស្លាកសញ្ញាមានរូបភាពដូច ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា
- ផ្នែកខាងក្រោមមានសរសេរអក្សរ "**គរុកោសល្យយោធាចារ្យ**" ពណ៌មាស។

+ រូបភាព និងខ្នាតស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាល ទាំង៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ មានក្នុងឧបសម្ព័ន្ធភ្ជាប់។

### ២. ការផលិត និងប្រើប្រាស់

ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាល ទាំង៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ សម្រាប់ដាក់លើអាវ ទង់ប្រចាំវគ្គនីមួយៗ ផលិតពីលោហធាតុ សម្រាប់សម្គាល់ជំនាន់វគ្គហ្វឹកហ្វឺននីមួយៗ និងផលិតជាវត្ថុអនុស្សាវរីយ៍ផ្សេងៗតាមទំហំជាក់ស្តែង។

ទំហំស្លាកសញ្ញា ផលិតតាមសមាមាត្រ និងទីតាំងនៃការប្រើប្រាស់។

**ប្រការ២ .~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ .~**

អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន មេបញ្ជាការប្រភេទទ័ព មេបញ្ជាការកងរាជអាវុធហត្ថ មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស នាយកនាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការកងឯកភាពពាក់ព័ន្ធ ត្រូវចូលរួមអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ✍

ថ្ងៃអង្គារ ៣រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍. ទៀ_សីហា**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ករជ
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន នៃ ខ.ភ.ម
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ..............................ចុះថ្ងៃទី..........ខែ.............ឆ្នាំ២០២៦
ស្តីពី ការរៀបចំស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាល ទាំង៨ជំនាញ របស់សាកលវិទ្យាល័យការពារជាតិ

**១. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលជំនាញការពារជាតិ**




| | |
|---|---|
| ស្លាកសញ្ញារាងចតុកោណស្មើ | កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម |
| - មែពណ៌មាសព័ទ្ធជុំវិញ | កម្រាស់ ០១ម.ម |
| - មកុដពណ៌មាស | កម្ពស់ ១០ម.ម និង ទទឹង ១០ម.ម |
| - អក្សរ "**យុទ្ធសាស្ត្រការពារជាតិ**" | កម្ពស់ ០១ម.ម |
| - រូបស្លាបសត្វ យុថ្កា ត្រីសូល៍ សៀវភៅបើក | កម្ពស់ ១៧ម.ម និង ទទឹង ២១ម.ម |
| - លេខសម្គាល់ជំនាន់នីមួយៗ | កម្ពស់ ០៣ម.ម |

## ២. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រយោធា



- ស្លាកសញ្ញារាងជាខែល កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម
- រឹមពណ៌មាសព័ទ្ធជុំវិញ កម្រាស់ ០១ម.ម
- អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" កម្ពស់ ០២ម.ម
- រូបមកុដ កម្ពស់ ០៧ម.ម និង ទទឹង ០៧ម.ម
- រូបសៀវភៅបើក កម្ពស់ ០៤ម.ម និង ទទឹង ១០ម.ម
- លេខសម្គាល់ជំនាន់នីមួយៗ កម្ពស់ ០៣ម.ម
- រូបកួរស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា កម្ពស់ ១៨ម.ម និង ទទឹង ២០ម.ម
- អក្សរ "**បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រយោធា**" កម្ពស់ ០១ម.ម

## ៣. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រនយោបាយ




| | |
|---|---|
| - ស្លាកសញ្ញារាងជាខែល | កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម |
| - ពែមពណ៌មាសព័ទ្ធជុំវិញ | កម្រាស់ ០១ម.ម |
| - អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" | កម្ពស់ ០២ម.ម |
| - រូបមកុដ | កម្ពស់ ០៨ម.ម និង ទទឹង ០៨ម.ម |
| - រូបសៀវភៅបើក | កម្ពស់ ០៥ម.ម និង ទទឹង ១១ម.ម |
| - លេខសម្គាល់ជំនាន់នីមួយៗ | កម្ពស់ ០៣ម.ម |
| - រូបកួរស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា | កម្ពស់ ២០ម.ម និង ទទឹង ២៣ម.ម |
| - អក្សរ "**បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រនយោបាយ**" | កម្ពស់ ០១ម.ម |

## ៤. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រព័ត៌មានវិទ្យា




| | |
|---|---|
| - ស្លាកសញ្ញាពងជាខែល | កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម |
| - រឹមពណ៌មាសព័ទ្ធជុំវិញ | កម្រាស់ ០១ម.ម |
| - អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" | កម្ពស់ ០២ម.ម |
| - រូបមកុដ | កម្ពស់ ០៧ម.ម និង ទទឹង ០៧ម.ម |
| - រូបសៀវភៅបើក | កម្ពស់ ០៤ម.ម និង ទទឹង ១០ម.ម |
| - លេខសម្គាល់ជំនាន់នីមួយៗ | កម្ពស់ ០៣ម.ម |
| - រូបកួរស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា | កម្ពស់ ១៨ម.ម និង ទទឹង ២០ម.ម |
| - រូបប្រព័ន្ធព័ត៌មានវិទ្យា | កម្ពស់ ០៤ម.ម និង [illegible] |
| - អក្សរ "**បរិញ្ញាបត្រព័ត៌មានវិទ្យា**" | កម្ពស់ ០២ម.ម |

### ៥. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រភស្តុភារយោធា



- ស្លាកសញ្ញារាងជាខែល កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម
- រឹមពណ៌មាសព័ទ្ធជុំវិញ កម្រាស់ ០១ម.ម
- អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" កម្ពស់ ០២ម.ម
- រូបមកុដ កម្ពស់ ០៧ម.ម និង ទទឹង ០៧ម.ម
- រូបសៀវភៅបើក កម្ពស់ ០៤ម.ម និង ទទឹង ១០ម.ម
- លេខសម្គាល់ជំនាន់នីមួយៗ កម្ពស់ ០៣ម.ម
- រូបក្សស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា កម្ពស់ ១៨ម.ម និង ទទឹង ២០ម.ម
- រូបសញ្ញាជំនាញភស្តុភារ កម្ពស់ ០៨ម.ម និង ទទឹង [illegible]
- អក្សរ "**បរិញ្ញាបត្រភស្តុភារយោធា**" កម្ពស់ ០២ម.ម

## ៦. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលបរិញ្ញាបត្រហិរញ្ញវត្ថុយោធា




| | | | | |
|---|---|---|---|---|
| - ស្លាកសញ្ញារាងជាខែល | កម្ពស់ | ៤០ម.ម | និង ទទឹង | ៣០ម.ម |
| - រឹមពណ៌មាសព័ទ្ធជុំវិញ | កម្រាស់ | ០១ម.ម | | |
| - អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" | កម្ពស់ | ០២ម.ម | | |
| - រូបមកុដ | កម្ពស់ | ០៧ម.ម | និង ទទឹង | ០៧ម.ម |
| - រូបសៀវភៅបើក | កម្ពស់ | ០៤ម.ម | និង ទទឹង | ១០ម.ម |
| - លេខសម្គាល់ជំនាន់នីមួយៗ | កម្ពស់ | ០៣ម.ម | | |
| - រូបក្សស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា | កម្ពស់ | ១៨ម.ម | និង ទទឹង | ២០ម.ម |
| - រូបសញ្ញាជំនាញកស្តុការ | កម្ពស់ | ០៨ម.ម | និង ទទឹង | ០៣ម.ម |
| - អក្សរ "**បរិញ្ញាបត្រហិរញ្ញវត្ថុយោធា**" | កម្ពស់ | ០២ម.ម | | |

## ៧. ស្លាកសញ្ញាសម្គាល់វគ្គបណ្ដុះបណ្ដាលបរិញ្ញាបត្រអប់រំចិត្តសាស្ត្រយោធា




- ស្លាកសញ្ញាកងផាខែល កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម
- រឹមពណ៌មាសព័ទ្ធជុំវិញ កម្រាស់ ០១ម.ម
- អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" កម្ពស់ ០២ម.ម
- រូបមកុដ កម្ពស់ ០៨ម.ម និង ទទឹង ០៨ម.ម
- រូបសៀវភៅបើក កម្ពស់ ០៥ម.ម និង ទទឹង ១១ម.ម
- លេខសម្គាល់ជំនាន់នីមួយៗ កម្ពស់ ០៣ម.ម
- រូបកួរស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា កម្ពស ២០ម.ម និង ទទឹង ២៣ម.ម
- អក្សរ "**បរិញ្ញាបត្រអប់រំចិត្តសាស្ត្រយោធា**" កម្ពស់ ០២ម.ម

## ៨. ស្លាកសញ្ញាសម្គាល់វគ្គបណ្តុះបណ្តាលគរុកោសល្យយោធាចារ្យ




- ស្លាកសញ្ញារាងជាខែល កម្ពស់ ៤០ម.ម និង ទទឹង ៣០ម.ម
- រឹមពណ៌មាសព័ទ្ធជុំវិញ កម្រាស់ ០១ម.ម
- អក្សរ "**សាកលវិទ្យាល័យការពារជាតិ**" កម្ពស់ ០២ម.ម
- រូបមកុដ កម្ពស់ ០៨ម.ម និង ទទឹង ០៨ម.ម
- រូបសៀវភៅបើក កម្ពស់ ០៥ម.ម និង ទទឹង ១១ម.ម
- លេខសម្គាល់ជំនាន់នីមួយៗ កម្ពស់ ០៣ម.ម
- រូបកួរស្រូវកោង កាំភ្លើងខ្វែង ស្លាបសត្វ យុថ្កា កម្ពស់ ២០ម.ម និង ទទឹង ២៣ម.ម
- អក្សរ "**គរុកោសល្យយោធាចារ្យ**" កម្ពស់ ០២ម.ម

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី